ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំស្តីពី ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គម ក្នុងកញ្ចប់គ្រួសារ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែកញ្ញា ឆ្នាំ២០២៣

# មាតិកា


**បញ្ជីតារាង** .................................................................................... I

**បញ្ជីរូបភាព** .................................................................................... II

**អារម្ភកថា** .................................................................................... III

**បុព្វកថា** .................................................................................... VI

**ខ្លឹមសារសង្ខេបប្រតិបត្តិ** .................................................................................... VIII

**១. សេចក្តីផ្តើម** .................................................................................... ១

១.១. ស្ថានភាពសង្គម និងប្រជាសាស្ត្រ .................................................................................... ២

១.២. ទិដ្ឋភាពច្បាប់ និងគោលនយោបាយ .................................................................................... ៤

**២. សន្និទានភាពក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** .................................................................................... ៦

២.១. ការបង្កើនប្រសិទ្ធភាព .................................................................................... ៦

២.២. ការឈានទៅគ្របដណ្តប់ជនងាយរងគ្រោះ តាមរយៈវិធីសាស្ត្រសមាហរណកម្ម .................................................................................... ៧

២.៣. មេរៀន និងបទពិសោធន៍ពីការឆ្លើយតបនឹងជំងឺកូវីដ-១៩ .................................................................................... ៨

**៣. គោលបំណង** .................................................................................... ១០

**៤. ទ្រឹស្តីនៃការផ្លាស់ប្តូរ** .................................................................................... ១៥

**៥. យន្តការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** .................................................................................... ១៦

៥.១. ការកំណត់ក្រុមគោលដៅ និងការកំណត់អត្តសញ្ញាណ .................................................................................... ១៦

៥.២. សិទ្ធិទទួលបានអត្ថប្រយោជន៍ និងលក្ខខណ្ឌនៃការបញ្ចូលក្នុងកម្មវិធី .................................................................................... ១៦

៥.៣. អត្ថប្រយោជន៍ លក្ខខណ្ឌ និងការបើកផ្តល់ .................................................................................... ១៧

៥.៤. ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ  និងសិទ្ធិផ្សេងទៀត .................................................................................... ១៩

៥.៥. លក្ខខណ្ឌនៃការចាកចេញ .................................................................................... ២០

**៦. ប្រព័ន្ធគាំទ្រការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** .................................................................................... ២១

៦.១. អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ និងការបង្កើនបរិយាបន្ន .................................................................................... ២១

៦.២. ពង្រឹងប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់ .................................................................................... ២១

៦.៣. ការបង្កើនភាពបត់បែន ភាពធន់ និងការឆ្លើយតបនឹងគ្រោះអាសន្ន .................................................................................... ២៣

**៧. យន្តការស្ថាប័ន** .................................................................................... ២៤

៧.១. ស្ថាប័នថ្នាក់ជាតិ .................................................................................... ២៤

៧.១.១.ក្រុមប្រឹក្សាជាតិគាំពារសង្គម និងអគ្គលេខាធិការដ្ឋាន .................................................................................... ២៤

៧.១.២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ អាណាព្យាបាល បច្ចេកទេស .................................................................................... ២៤

៧.១.៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ អាណាព្យាបាលហិរញ្ញវត្ថុ .................................................................................... ២៥

៧.១.៤. ក្រសួងផែនការ ..... ២៥
៧.១.៥. ក្រសួងមហាផ្ទៃ ..... ២៦
៧.១.៦. ក្រសួងសុខាភិបាល ..... ២៦
៧.១.៧. ក្រសួងអប់រំ យុវជន និងកីឡា ..... ២៦
៧.១.៨. មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) ..... ២៧
៧.២. រដ្ឋបាលថ្នាក់រាជធានី-ខេត្ត ..... ២៧
៧.២.១. រដ្ឋបាលរាជធានី-ខេត្ត ..... ២៨
៧.២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ..... ២៨
៧.២.៣. មន្ទីរសុខាភិបាលរាជធានី ខេត្ត ..... ២៨
៧.២.៤. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ..... ២៨
៧.២.៥. គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (គ.ក.ស.ក.) រាជធានី ខេត្ត ..... ២៨
៧.៣. ថ្នាក់ក្រុង ស្រុក ខណ្ឌ ..... ២៩
៧.៣.១. គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ ..... ២៩
៧.៣.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ..... ២៩
៧.៤. ថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិ ..... ២៩
៧.៤.១. ក្រុមប្រឹក្សាឃុំ សង្កាត់ ..... ២៩
៧.៤.២. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ..... ២៩
៧.៤.៣. សាលារៀន ..... ២៩
៧.៤.៤. មណ្ឌលសុខភាព ..... ៣០
៧.៤.៥. ក្រុមតំណាងភូមិ និងក្រុមគាំទ្រសុខភាពភូមិ ..... ៣០
៧.៤.៦. ភាពជាដៃគូ ..... ៣០
**៨. សកម្មភាពអន្តរកាល និងការត្រៀមខ្លួន ..... ៣១**
៨.១. ការអភិវឌ្ឍប្រព័ន្ធ និងសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ..... ៣១
៨.២. ការរៀបចំឯកសារបណ្តុះបណ្តាល ..... ៣២
៨.៣. ការបណ្តុះបណ្តាលមន្ត្រីអនុវត្តកម្មវិធី ..... ៣២
៨.៤. ការបញ្ជ្រាបការយល់ដឹង និងការកៀរគរការចូលរួម ..... ៣៣
**៩. វដ្តប្រតិបត្តិការ និងជំហាននៃកម្មវិធី ..... ៣៥**
៩.១. ការកំណត់អត្តសញ្ញាណក្រុមគោលដៅ និងការចុះឈ្មោះចូលកម្មវិធី ..... ៣៥
៩.២. ការអនុវត្តលក្ខខណ្ឌ អនុម័ត និងការបើកផ្តល់ ..... ៣៦

៩.៣. ការគ្រប់គ្រងករណី ........................................................................ ៣៦
៩.៤. ការផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ និងការរាយការណ៍ .................................................. ៣៧
៩.៥. ការដោះស្រាយបណ្តឹងតវ៉ា.................................................................. ៣៧
៩.៥.១. បញ្ហាបច្ចេកទេសដែលកើតឡើងជាប្រចាំ ................................................ ៣៧
៩.៥.២. ការដោះស្រាយបណ្តឹងតវ៉ា និងវិវាទ ..................................................... ៣៨
៩.៦. ការតាមដាន និងការវាយតម្លៃ ............................................................. ៣៨
៩.៦.១. ការតាមដាន ............................................................................. ៣៨
៩.៦.២. ការវាយតម្លៃ............................................................................. ៣៩
**១០. ផែនការសមាហរណកម្ម និងការពង្រីកវិសាលភាព**.......................................... ៤០
**១១. សេចក្តីសន្និដ្ឋាន** ........................................................................... ៤១
**សន្ទានុក្រម** ..................................................................................... ៤២

# បញ្ជីតារាង

តារាងទី១៖  កម្រិតអត្ថប្រយោជន៍ និងចំនួនលើកនៃការបើកផ្តល់ និងលក្ខខណ្ឌ .................. ១៧
តារាងទី២៖  វដ្តនៃការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ .... ១៩

# បញ្ជីរូបភាព


រូបភាពទី១៖ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ...................................... ១០
រូបភាពទី២៖ ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ..... ១៥
រូបភាពទី៣៖ ក្របខណ្ឌសមាហរណកម្មប្រព័ន្ធជំនួយសង្គម ........................................... ២២
រូបភាពទី៤៖ វដ្តប្រតិបត្តិការ ........................................................................... ៣៥
រូបភាពទី៥៖ ការបើកផ្តល់ និងលក្ខខណ្ឌ ............................................................... ៣៦
រូបភាពទី៦៖ ការគ្រប់គ្រងករណី ......................................................................... ៣៧

# អារម្ភកថា

ជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍, កម្ពុជាបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងបន្តបោះជំហាននៃការអភិវឌ្ឍទៅមុខ។ ការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ តាមរយៈការវិនិយោគលើវិស័យសុខាភិបាល, វិស័យអប់រំ ក៏ដូចជាប្រព័ន្ធគាំពារសង្គម ជាដើម បានធ្វើឱ្យអត្រាភាពក្រីក្រធ្លាក់ចុះពី ៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹមប្រមាណជាង ១៧,៨% នៅឆ្នាំ២០២០ ហើយផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ បានឈានដល់ **១ ៧៨៤ ដុល្លារអាមេរិក** នៅឆ្នាំ ២០២២។

ជាការសម្លឹងទៅមុខ និងដើម្បីសម្រេចក្តីប្រាថ្នាក្នុងការប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០, គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា នៅតែបន្តផ្តោតលើ **មនុស្ស** ជាចម្បង។ ផ្លែផ្កានៃកំណើន បូករួមនឹងស្ថិរភាពនយោបាយ និងសុខសន្តិភាពពេញលេញ បានអនុញ្ញាតឱ្យកម្ពុជាដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ ក៏ដូចជាអនុវត្តការងារកែទម្រង់សំខាន់ៗដើម្បីស្តារ និងអភិវឌ្ឍប្រទេស ដោយសម្រេចបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ។ ជាក់ស្តែងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលជាក្របខណ្ឌមួយដ៏សំខាន់បានជំរុញការកសាងប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាពដោយឈរលើស្មារតី "មិនបោះបង់ពលរដ្ឋណាម្នាក់" និងឈរលើគោលការណ៍ជាក់លាក់ ដែលរួមមានចីរភាពនៃកម្មវិធី, លទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ, ការធានានូវបរិយាបន្ន និងសមធម៌សង្គមដោយផ្តោតកិច្ចអន្តរាគមន៍របស់រដ្ឋលើគ្រួសារក្រីក្រ និងងាយរងគ្រោះ, និងភាពអាចពង្រីកបាននៃទំហំប្រព័ន្ធគាំពារសង្គម តាមរយៈការអភិវឌ្ឍជាប្រព័ន្ធ។

តាមរយៈការដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត ក៏ដូចជាពង្រឹង និងពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គមមួយចំនួន ដែលក្នុងនោះកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ជាកម្មវិធីជាតិជំនួយសង្គមដំបូងគេ ដែលមានវិសាលភាពទូទាំងប្រទេស និងត្រូវបានដាក់ឱ្យដំណើរការតាំងពីឆ្នាំ ២០១៩។ បទពិសោធន៍ និងយន្តការអនុវត្តកម្មវិធីជាតិជំនួយសង្គមនេះ បានផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្សេងទៀត និងបន្តអភិវឌ្ឍប្រព័ន្ធជំនួយសង្គមឱ្យកាន់តែរឹងមាំ ស្របពេលដែលប្រព័ន្ធសន្តិសុខសង្គមក៏កំពុងត្រូវបានអនុវត្តប្រកបដោយវឌ្ឍនភាព។

ដោយឡែក, វិបត្តិនៃជំងឺកូវីដ-១៩ មិនត្រឹមតែបានបង្កការគំរាមកំហែងដល់សុខភាព និងអាយុជីវិតរបស់ពលរដ្ឋប៉ុណ្ណោះទេ ថែមទាំងបានបង្កផលជះអវិជ្ជមានផ្នែកសេដ្ឋកិច្ច-សង្គមជាច្រើន។ បន្ថែមលើនេះ, សម្ពាធដែលកើតចេញពីជម្លោះរុស្ស៊ី-អ៊ុយក្រែន ក៏បានជះឥទ្ធិពលអវិជ្ជមានលើជីវភាព

របស់ពលរដ្ឋ ខណៈឥទ្ធិពលនៃជំងឺកូវីដ-១៩ មិនទាន់ផុតរលត់ទាំងស្រុងនៅឡើយ។ ទោះយ៉ាងណា, ក្រោមមគ្គុទេសក៍ដឹកនាំដ៏វៃឆ្លាត ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កន្លងមក, កម្ពុជាអាចបង្កើតបាននូវភាពស៊ាំសហគមន៍ពេញលេញ និងរឹងមាំ ដោយមានពលរដ្ឋជាង ៩០% បានទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងបានដាក់ចេញនូវវិធានការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច-សង្គមទាន់ពេល និងចំគោលដៅ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាលំនឹងជីវភាព។ ក្នុងអំឡុងពេលនៃវិបត្តិទាំងនេះ, រាជរដ្ឋាភិបាលបានបន្តអនុវត្តរាល់កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមទាំងអស់ជាប្រក្រតី ក្នុងការផ្តល់អត្ថប្រយោជន៍ជូនអ្នកទទួលផល ហើយថែមទាំងបានដាក់ចេញនូវកម្មវិធីជំនួយសង្គមពិសេសមួយចំនួនបន្ថែម សំដៅជួយសម្រួលជីវភាពរបស់ពលរដ្ឋ ក្នុងគ្រាមានវិបត្តិ រួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ទ្រង់ទ្រាយធំសម្រាប់ពលរដ្ឋ និងគ្រួសារពលរដ្ឋ មានការលំបាកផ្នែកជីវភាព, ពលរដ្ឋ និងគ្រួសារពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩, កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់។ នៅពេលវិបត្តិបានថមថយ និងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលបញ្ចប់ការអនុវត្តកម្មវិធីជំនួយសង្គមពិសេសទាំងនេះ ជាជំហានៗ, ការបន្តទ្រទ្រង់គ្រួសារក្រីក្រ និងជនងាយរងគ្រោះទាំងនេះ នៅតែមានភាពចាំបាច់។

ជាមួយគ្នានេះ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក៏បានចង្អុលបង្ហាញឱ្យរៀបចំក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមជាកញ្ចប់គ្រួសារ ដែលជាការប្រមូលផ្តុំកម្មវិធីជំនួយសង្គមមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ឱ្យមកអនុវត្តបែបសមាហរណ៍ ក្នុងក្របខណ្ឌតែមួយ ក្នុងគោលដៅពង្រឹងអភិបាលកិច្ច និងបង្កើនប្រសិទ្ធភាព ក៏ដូចជាបង្កើនសង្គតិភាព និងពង្រីកការគ្របដណ្តប់ឱ្យកាន់តែទូលាយដល់គ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះក្នុងគ្រួសារក្រីក្រ ដែលរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានចាត់ទុកថា ជាធាតុនៃគោលនយោបាយអាទិភាពមួយក្នុងចំណោមគោលនយោបាយអាទិភាពទាំង៦។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចធ្វើស្ថាបនូបនីយកម្ម តាមរយៈ "**គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**" នេះ នូវកម្មវិធីជាតិជំនួយសង្គម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, ស្វ័យប្រវត្តិ, និងអនុវត្តក្នុងទម្រង់រួមមួយ។

**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នេះ ជាសមាសភាគនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលមានគោលបំណងកំណត់យុទ្ធសាស្ត្រ និងធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គម ក្នុងគោលដៅបង្កើនសង្គតិភាព, ប្រសិទ្ធភាព, តម្លាភាព តាមរយៈការរៀបចំឱ្យមានលិខិតបទដ្ឋាន និងនីតិវិធីសម្រាប់អនុវត្ត ក៏ដូចជាកំណត់អំពីតួនាទី និងភារកិច្ចរបស់

ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការចូលរួមអនុវត្តប្រកបដោយជោគជ័យ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នេះ នឹងតម្រែតម្រង់ការអនុវត្ត ក៏ដូចជារួមចំណែកដល់ការពង្រឹង និងពង្រីកវិសាលភាពប្រព័ន្ធគាំពារសង្គម ព្រមទាំងរួមចំណែកសម្រេចបាននូវគោលបំណងនៃកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

ថ្ងៃពុធ ៦កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បុព្វកថា

ប្រព័ន្ធគាំពារសង្គមជាសសរស្តម្ភដែលរួមចំណែកយ៉ាងសំខាន់ ក្នុងការកសាងសង្គមមួយប្រកបដោយភាពសុខដុម និងជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ និងអភិវឌ្ឍប្រទេសឱ្យមានភាពធន់, រឹងមាំ, និរន្តរភាព, សមធម៌ និងបរិយាបន្ន ក៏ដូចជាជួយឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងស្មារតីនេះ, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត និងបានក្លាយជាឯកសារផែនទីបង្ហាញផ្លូវសម្រាប់ការកសាងប្រព័ន្ធគាំពារសង្គមកម្ពុជា ដែលមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព និងចីរភាព។

ដើម្បីសម្រេចបានចក្ខុវិស័យវែងឆ្ងាយ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយដ៏រឹងមាំនៅព្រះរាជាណាចក្រកម្ពុជា, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានចង្អុលបង្ហាញឱ្យមានការរៀបចំប្រព័ន្ធជំនួយសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងសមាហរណៃ ដោយរៀបចំបង្កើតក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលជាក្របខណ្ឌមានយន្តការអនុវត្តរួម និងមានសង្គតិភាព ដែលដឹកនាំអនុវត្តដោយមូលនិធិជាតិជំនួយសង្គមដែលជាប្រតិបត្តិករទោល និងមានការចូលរួមគាំទ្រអនុវត្តដោយក្រសួង-ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ និងក្រោមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាល, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានរៀបចំ "**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**" សម្រាប់អនុវត្តកម្មវិធីជាតិជំនួយសង្គម ដែលរួមមានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឆ្នាំឡើង), កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព និងការឧបត្ថម្ភសាច់ប្រាក់គោល សម្រាប់គ្រួសារមានបណ្ណសមធម៌ទាំងអស់ ព្រមទាំងគិតគូរដល់សមាជិកគ្រួសារដែលរស់នៅជាមួយមេរោគ/ជំងឺអេដស៍ ក្នុងកញ្ចប់តែមួយ និងដែលដាក់ឱ្យអនុវត្តដោយគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល នេះ។

"**គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**" កំណត់នូវយុទ្ធសាស្ត្រ និងការធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គម ដោយផ្តោតលើការបង្កើនស័ក្តិសិទ្ធិភាពប្រតិបត្តិការ និងប្រសិទ្ធភាពចំណាយក្នុងការផ្តល់ជំនួយសង្គម ដែលឆ្លើយតបនឹងតម្រូវការរបស់បុគ្គលក្នុងវដ្តជីវិត ហើយផ្តល់ដំណោះស្រាយគ្រប់ជ្រុងជ្រោយចំពោះហានិភ័យ និងភាពងាយរងគ្រោះនានា។ ការរៀបចំក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានគោលបំណងផ្តល់ការគាំទ្ររួមបន្ថែមទៀតដល់គ្រួសារ និងបុគ្គលងាយរងគ្រោះ តាមរយៈការរៀបចំដំណើរការអនុវត្ត និងការកំណត់លក្ខខណ្ឌដែលមានភាពសាមញ្ញ សម្រួលដល់ការទទួលផល ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវយន្តការកំណត់ក្រុមគោលដៅដែលត្រូវទទួលផលជាដើម។

ការរៀបចំបង្កើតក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជាការបោះជំហានថ្មីមួយទៀតក្នុងការកែទម្រង់ប្រព័ន្ធគាំពារសង្គម ដោយជំរុញការប្រមូលផ្តុំកម្មវិធី តាមរយៈសមាហរណកម្មមុខងាររបស់កម្មវិធី មកក្រោមប្រតិបត្តិករទោល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃ

ការគ្រប់គ្រងមួយកម្រិតទៀត ក្នុងការផ្ដោតការគ្របដណ្ដប់ ស្របតាមអភិក្រមហានិភ័យនៃវដ្ដជីវិត (Life-cycle Risk Approach) ដែលជាទិសដៅក្នុងការកសាងប្រព័ន្ធគាំពារសង្គមកម្ពុជា ក្នុងដំណាក់កាលបន្ទាប់។

ដំណើរនៃការរៀបចំឯកសារ **គោលការណ៍ណែនាំស្ដីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នេះ ទទួលបានកិច្ចសហការយ៉ាងជិតស្និតពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងភាពជាម្ចាស់។ ផ្អែកលើការខិតខំ ពីគ្រប់ភាគីពាក់ព័ន្ធ, គោលការណ៍ណែនាំស្ដីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះ ត្រូវបានរៀបចំគ្រប់ជ្រុងជ្រោយ និងទទួលបានការឯកភាពពីក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងកិច្ចប្រជុំកាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ និងបានទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលដែលមាន **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី**។

ក្នុងនាមក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារ និងថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដែលបានផ្ដល់កិច្ចសហការ និងធាតុចូលសម្រាប់រៀបចំគោលការណ៍ណែនាំ ស្ដីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះ មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF), សហភាពអឺរ៉ុប, ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) និងមូលនិធិសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG-Fund) ដែលបានផ្ដល់ជំនួយបច្ចេកទេស និងការគាំទ្រដំណើរការនៃការរៀបចំដែលនាំឱ្យឯកសារនេះ មានភាពគ្រប់ជ្រុងជ្រោយ និងលេចចេញជារូបរាងឡើង។

ថ្ងៃ ចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមជាបន្តបន្ទាប់ ក្នុងការផ្តល់កិច្ចគាំពារដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ស្របតាមហានិភ័យនៃវដ្តជីវិត គិតពីពេលចាប់កំណើតរហូតដល់ទទួលមរណភាព ដើម្បីពង្រឹងស្ថានភាពគ្រួសារ, កាត់បន្ថយនិងទប់ស្កាត់ការធ្លាក់ក្នុងភាពក្រីក្រ, កសាងសង្គមដែលមានភាពធន់, និងពន្លឿនការអភិវឌ្ឍមូលធនមនុស្សប្រកបដោយបរិយាបន្ន និងចីរភាព ដោយឈរលើគោលការណ៍ **"មិនបោះបង់ពលរដ្ឋណាម្នាក់"**។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានចង្អុលបង្ហាញឱ្យមានការរៀបចំក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដោយធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គមទាំងអស់ ដើម្បីពង្រីកការគ្របដណ្តប់, បង្កើនប្រសិទ្ធភាព, និងការវិនិយោគហិរញ្ញវត្ថុ។

កម្មវិធី ដែលត្រូវធ្វើសមាហរណកម្មចូលក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ រួមមាន កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព, កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនចាស់ជរាអាយុចាប់ពី៦០ឆ្នាំឡើង, ការឧបត្ថម្ភសាច់ប្រាក់ជូនអ្នកផ្ទុកមេរោគ/ជំងឺអេដស៍ និងការឧបត្ថម្ភសាច់ប្រាក់គោលសម្រាប់គ្រួសារមានបណ្ណសមធម៌។

**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** ដំណើរការដោយមានការគាំទ្រពីយន្តការនៃការអនុវត្តកម្មវិធីមួយចំនួនទៀត រួមមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ, ការពង្រឹងប្រព័ន្ធបញ្ជូនបន្ត (Referrals) និងបណ្តាញតភ្ជាប់(Linkages) ទៅកាន់សេវា និងកម្មវិធីផ្សេងៗ និងការបង្កើនភាពបត់បែន និងភាពធន់ ក៏ដូចជាការឆ្លើយតបនឹងគ្រោះអាសន្ន។

ការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដំណើរការដោយប្រើប្រាស់យន្តការដឹកនាំ និងសម្របសម្រួលការងារអន្តរស្ថាប័ន ដែលមានមូលនិធិជាតិជំនួយសង្គមជាប្រតិបត្តិករ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាស្ថាប័នគាំទ្រ និងសហការអនុវត្តក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នេះ ផ្តល់នូវកញ្ចប់ជំនួយសង្គមចាំបាច់សម្រាប់គាំពារគ្រួសារដែលមានបណ្ណសមធម៌ តាមរយៈការឧបត្ថម្ភគោលដល់គ្រួសារ និងក្រុមជនងាយរងគ្រោះ ដូចជាស្ត្រីមានផ្ទៃពោះ, កុមារអាយុក្រោម២ឆ្នាំ, កូនៗជាសិស្ស, ជនមានពិការភាព, ជនចាស់ជរា និងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ យន្តការ និងនីតិវិធីនៃការអនុវត្តកម្មវិធីដំណើរការឡើងដោយការកំណត់ក្រុមគោលដៅ, ការចុះឈ្មោះចូលក្នុងកម្មវិធី, ការអនុវត្តលក្ខខណ្ឌ, ការអនុម័តការបើកផ្តល់, ការគ្រប់គ្រងករណី, ការដោះស្រាយបណ្តឹងតវ៉ា និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ជារួម គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជាការចង្អុលបង្ហាញនូវយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែង ដើម្បីធានាបាននូវភាពប្រទាក់ក្រឡា, គ្រប់ជ្រុងជ្រោយ និងការពង្រីកវិសាលភាពនៃកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនការគាំពារដល់គ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះពេញវដ្តជីវិត ប្រកបដោយបរិយាបន្ន ស្របតាមកំណែទម្រង់នីមួយៗដែលមានកំណត់ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ និងភាពស៊ីសង្វាក់គ្នារវាងស្ថាប័នជាប្រតិបត្តិករនិងស្ថាប័នគាំទ្រការអនុវត្ត។

## ១. សេចក្តីផ្តើម

ផ្លែផ្កានៃកំណើនសេដ្ឋកិច្ច បានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកាន់តែខ្លាំងឡើង។ ជាក់ស្តែងការដាក់ចេញនូវ "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**" ជាការកំណត់គោលដៅអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ មានសង្គតិភាព និងបរិយាបន្ន។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានកំណត់យកអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ដោយផ្អែកលើសសរស្តម្ភចំនួន ២ គឺប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។ ប្រព័ន្ធជំនួយសង្គម ជាអន្តរាគមន៍របស់រដ្ឋដែលរៀបចំ និងដាក់ឱ្យដំណើរការដើម្បីជួយលើកស្ទួយជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ សំដៅលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស, អាហារូបត្ថម្ភ, និងសុខុមាលភាព ក្រោមទិដ្ឋភាពជាការឧបត្ថម្ភសាច់ប្រាក់ និងមិនមែនសាច់ប្រាក់។ ផ្អែកលើស្មារតីនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមជាបន្តបន្ទាប់ រួមមាន៖ (១)កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, (២)កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា, (៣)កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព, (៤)កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍, និង (៥)កម្មវិធីជំនួយសង្គមពិសេសឆ្លើយតបនឹងគ្រោះអាសន្ននានា។

ជាក់ស្តែង ការដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គម បានចាប់ផ្តើមតាំងពីមុនពេលដែលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តមកម្ល៉េះ ប៉ុន្តែការគ្រប់គ្រង និងចាត់ចែងកម្មវិធីទាំងនោះនៅមានភាពរាយប៉ាយនៅឡើយ។ ផ្អែកលើកត្តានេះ, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានចង្អុលឱ្យមានការគិតគូរ និងរៀបចំឡើងវិញនូវយន្តការគ្រប់គ្រងកម្មវិធីមួយដែលមានលក្ខណៈប្រមូលផ្តុំ ជាពិសេស ត្រូវចាប់ផ្តើមពីការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ ឱ្យស្ថិតនៅក្រោមយន្តការតែមួយ ពោលគឺការបង្កើត និងដាក់ឱ្យដំណើរការ "**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**" ដែលជាទិសដៅចម្បងនៃគោលការណ៍ណែនាំនេះ។

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជាក្របខណ្ឌដែលមានលក្ខណៈសមាហរណៈ និងត្រូវបានរៀបចំឡើងសម្រាប់គាំទ្រគ្រួសារក្រីក្រ និងងាយរងគ្រោះទូទាំងប្រទេស ដើម្បីការពារ និងទប់ស្កាត់ការធ្លាក់ចូលជ្រៅទៅក្នុងភាពក្រីក្រ, ពន្លឿនការប្រមូលផ្តុំការអភិវឌ្ឍមូលធនមនុស្ស, និងលើកកម្ពស់កំណើនប្រកបដោយបរិយាបន្ន ដោយឈរលើស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**"។

គោលបំណងសំខាន់នៃឯកសារគោលការណ៍ណែនាំនេះ បង្ហាញពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, ការបង្កើតឱ្យមាន និងការអនុវត្ត ដែលគ្របដណ្តប់គ្រប់ជ្រុងជ្រោយ នូវរាល់តម្រូវការរបស់គ្រួសារពេញវដ្តជីវិត, ផ្តល់លទ្ធភាពឱ្យពួកគេអាចជំនះភាពក្រីក្រ ភាពលំបាក និងភាពងាយរងគ្រោះ ក៏ដូចជាវិនិយោគលើមូលធនមនុស្ស ដើម្បីពន្លឿនកំណើនប្រកបដោយចីរភាព និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន។

**គោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នេះ មាន ១១ផ្នែក គឺ៖ **ផ្នែកទី១** បង្ហាញអំពីក្របខណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់ប្រព័ន្ធគាំពារសង្គម និងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលជាទិដ្ឋភាពទូទៅនៃប្រព័ន្ធគាំពារសង្គម, **ផ្នែកទី២** បង្ហាញអំពីសនិទានភាពនៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, **ផ្នែកទី៣** បង្ហាញអំពីគោលបំណងនៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, **ផ្នែកទី៤** បង្ហាញពីទ្រឹស្តីនៃការផ្លាស់ប្តូរ, **ផ្នែកទី៥** បង្ហាញអំពីការរៀបចំកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ហើយប្រព័ន្ធគាំទ្រការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានក្នុង **ផ្នែកទី៦**, **ផ្នែកទី៧** បង្ហាញអំពីយន្តការស្ថាប័នជាមួយនឹងសកម្មភាពអន្តរកាល មានក្នុង **ផ្នែកទី៨**, **ផ្នែកទី៩** បង្ហាញពីវដ្តនៃប្រតិបត្តិការ និងជំហាននានានៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, **ផ្នែកទី១០** បង្ហាញអំពីផែនការសមាហរណកម្ម និងពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងចុងក្រោយ **ផ្នែកទី១១** ជាសេចក្តីសន្និដ្ឋាន។

## ១.១. ស្ថានភាពសង្គម និងប្រជាសាស្ត្រ

ការវិនិយោគលើការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម ក្នុងរយៈពេល ១ទសវត្សរ៍ចុងក្រោយនេះ នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានផ្លែផ្កាគួរជាទីមោទនៈ។ ទោះជាយ៉ាងនេះក្តី នៅតែមានបញ្ហាប្រឈមមួយចំនួនដែលរាំងរស្ទះការអភិវឌ្ឍ ហើយគ្រួសារជាច្រើននៅតែស្ថិតក្នុងហានិភ័យ ឬស្ថិតនៅក្បែរបន្ទាត់នៃភាពក្រីក្រនៅឡើយ។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា នាពេលថ្មីៗនេះ បានសបញ្ជាក់ឱ្យឃើញអំពីស្ថានភាពជាក់ស្តែងរបស់ពលរដ្ឋម្នាក់ៗ និងបង្ហាញពីបញ្ហាប្រឈមមួយចំនួនក្នុងវដ្តជីវិតរបស់ពួកគេ។

កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារតូចអាយុក្រោម៥ឆ្នាំ បានបង្កឱ្យមានក្តីបារម្ភយ៉ាងខ្លាំង ដោយហេតុថា ស្ថានភាពអាហារូបត្ថម្ភសម្រាប់កុមារនៅមិនទាន់មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅឡើយ ទោះបីជាមាននិន្នាការកើនឡើងនៃការប្រើប្រាស់ជាទូទៅ (overall consumption) និងការកាត់បន្ថយភាពក្រីក្រមានភាពប្រសើរឡើងចាប់តាំងពីឆ្នាំ២០០៤មក ក៏ដោយ។ លើសពីនេះ កត្តាអនាម័យ, ទឹកស្អាត, សេវាសុខាភិបាល, និងការអប់រំ នៅតែជាបញ្ហាប្រឈម ដែលអាចធ្វើឱ្យមានផលជះអវិជ្ជមានកាន់តែធ្ងន់ធ្ងរផងដែរ។

កុមារដែលមិនបានចូលរៀន មានហានិភ័យខ្ពស់ក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើតប្រាក់ចំណូល ឬធ្វើការងារតាមផ្ទះដែលមិនទទួលបានប្រាក់ឈ្នួល។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩-២០២០ បង្ហាញថា ក្នុងឆ្នាំ ២០១៤, គ្រួសារចំនួន ១២ ៩៩៧ បានឱ្យកូនឈប់រៀន ដោយសារពួកគេមិនមានអាហារគ្រប់គ្រាន់ ខណៈដែលកុមារអាយុពី ៦-១៧ឆ្នាំ ប្រមាណ ៤៥,៨% មិនបានចូលរៀន ដោយសារពួកគេត្រូវចូលរួមរកប្រាក់ចំណូលគ្រួសារ។ ខណៈដែលអត្រាពលកម្មកុមារបានធ្លាក់ចុះពាក់កណ្តាលចាប់តាំងពីឆ្នាំ២០០០មក, ទំនាក់ទំនងបញ្ច្រាសទិសរវាងការចុះឈ្មោះចូលរៀន និងពលកម្មកុមារ នៅតែត្រូវការកិច្ចខិតខំដើម្បីលុបបំបាត់។ កុមារអាយុ១៥-២៤ឆ្នាំ ប្រមាណ ៤% មិនបានចុះឈ្មោះចូលរៀន និងគ្មានការងារធ្វើ ក្នុងនោះកុមារនៅតំបន់ទីប្រជុំជនមានហានិភ័យខ្ពស់ជាងនៅទីជនបទ។ លើសពីនេះ កម្រិតទាបនៃការចុះឈ្មោះចូលរៀន ជាពិសេស

នៅកម្រិតមធ្យមសិក្សា បានបណ្ដាលឱ្យកម្មករវ័យក្មេងប្រមាណ ៤២,៥% បំពេញការងារជាមួយនឹងផលិតភាពនៅមានកម្រិត។ លើសពីនេះ កម្ពុជាក៏នៅមានកុមារដែលកំពុងរស់នៅតាមដងផ្លូវផងដែរ។

ព័ត៌មានអំពីស្ថានភាពជនអនាថា និងកុមារតាមដងផ្លូវ មានតិចតួច។ កុមារតាមដងផ្លូវ និងជនអនាថាបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយភាពក្រីក្រធ្ងន់ធ្ងរ និងការផាត់ចេញពីសង្គម (Social Exclusion)។ ពួកគេងាយប្រឈមបញ្ហាកង្វះអាហារូបត្ថម្ភ, ការអប់រំ, និងសេវាសំខាន់ៗផ្សេងទៀត ហើយមានហានិភ័យខ្ពស់ក្នុងអំពើជួញដូរ, អំពើហិង្សា, និងការរំលោភបំពាន។

នៅពេលកាន់តែជរា ពួកគេកាន់តែងាយប្រឈមនឹងហានិភ័យ និងភាពងាយរងគ្រោះជាច្រើន រួមទាំងកង្វះស្ថិរភាពប្រាក់ចំណូល, បណ្ដាញសង្គមខ្សត់ខ្សោយ, បញ្ហាសុខភាព, ពិការភាព, កង្វះការគាំទ្រ, និងការទទួលបានសេវាសំខាន់ៗជាដើម។ កង្វះស្ថិរភាពប្រាក់ចំណូលក្នុងពេលចូលនិវត្តន៍បង្កឱ្យមានភាពលំបាកខ្វះខាត ឬចាំបាច់ត្រូវបន្តធ្វើការងារក្នុងវ័យជរា។ មនុស្សវ័យចាស់ភាគច្រើនក្នុងប្រទេសកម្ពុជានៅបន្តសកម្មភាពសេដ្ឋកិច្ច ជាបុគ្គលស្វ័យនិយោជន៍ ឬធ្វើការងារជាលក្ខណៈគ្រួសារដែលមិនទទួលបានប្រាក់ឈ្នួល។ លើសពីនេះ ផលប៉ះពាល់ពីចំណាកស្រុក, នគរូបនីយកម្ម, និងការផ្លាស់ប្ដូររចនាសម្ព័ន្ធគ្រួសារ បានដាក់សម្ពាធកាន់តែខ្លាំងលើមនុស្សវ័យចាស់ ដោយសារពួកគេភាគច្រើនត្រូវបានទុកឱ្យមើលថែទាំកុមារតូចៗ និងពឹងផ្អែកខ្លាំងលើប្រាក់បញ្ញើពីកូនចៅនៅបរទេសសម្រាប់ចិញ្ចឹមជីវិត។ ដោយគួបផ្សំជាមួយនឹងអាជីពដែលងាយរងគ្រោះ, ការងារតាមរដូវកាល, ការសន្សំទាប និងការបន្តធ្វើការងារក្នុងវ័យជរា, ការផ្គត់ផ្គង់ជីវភាពសម្រាប់មនុស្សវ័យចាស់ជាច្រើនមានសារៈសំខាន់។

ប្រទេសកម្ពុជាកំពុងឈានក្លាយទៅជាប្រទេសដែលមានពលរដ្ឋវ័យចាស់ច្រើន (Ageing) ដូចបណ្ដាប្រទេសជាច្រើននៅលើពិភពលោក។ កម្ពុជាត្រូវបានរំពឹងថានឹងប្រមូលផលភាគលាភប្រជាសាស្ត្រដល់ឆ្នាំ២០៤៥ ហេតុដល់ពេលមួយដែលចំនួនពលរដ្ឋចាស់ជរាចាប់ផ្ដើមកើនឡើងយ៉ាងឆាប់រហ័សគួបផ្សំជាមួយនឹងអត្រាកំណើតទាប ដែលធ្វើឱ្យអត្រាទ្រទ្រង់មនុស្សចាស់ធ្លាក់ចុះ។ អត្រាទ្រទ្រង់មនុស្សចាស់នឹងថយចុះធៀបនឹងអត្រាទ្រទ្រង់កុមារនៅឆ្នាំ២០៩៦ នៅពេលដែលចំណែកពលរដ្ឋអាយុចាប់ពី៦០ឆ្នាំឡើង មានចំនួនប្រមាណ ២៤% នៃចំនួនពលរដ្ឋសរុប ដែលតួលេខនេះមានទំហំលើស **៥ ដង** ធៀបនឹងឆ្នាំ២០១៦។ ការផ្លាស់ប្ដូរស្ថានភាពប្រជាសាស្ត្រនេះ នឹងក្លាយជាបញ្ហាប្រឈម ដែលការវិនិយោគលើការបង្កើតប្រព័ន្ធជំនួយសង្គមដ៏រឹងមាំ អាចជួយកាត់បន្ថយហានិភ័យនេះបាន។

បន្ថែមពីនេះ ពិការភាពជាកត្តាចម្បងនៃហានិភ័យ និងភាពងាយរងគ្រោះ។ នៅជុំវិញពិភពលោក និងក្នុងប្រទេសកម្ពុជា, ជនមានពិការភាពប្រឈមនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវាសំខាន់ៗ ដូចជាសេវាសុខាភិបាល, អប់រំ, ការងារ, និងមធ្យោបាយធ្វើដំណើរ ជាដើម។ ការប៉ាន់ស្មានចំនួនជនមានពិការភាពក្នុងប្រទេសកម្ពុជាមានភាពខុសគ្នា ដោយសារការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នាក្នុងការកំណត់អត្តសញ្ញាណជនមានពិការភាព។ ការសិក្សាថ្មីមួយបានរកឃើញថា គ្រួសារដែលមានសមាជិកមានពិការភាព ត្រូវការប្រាក់ចំណូលជាមធ្យម ១៧% បន្ថែម ដើម្បីសម្រេចបាននូវកម្រិតជីវភាពដូចគ្រួសារធម្មតាផ្សេងទៀត។ បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងដាក់ឱ្យដំណើរការយន្តការអត្តសញ្ញាណកម្មពិការភាពថ្មីមួយ ដែលនឹងជួយបង្កើនបរិយាបន្នភាពចំពោះជនមានពិការភាព។

ខណៈដែលបុគ្គល និងគ្រួសារប្រឈមនឹងហានិភ័យ និងភាពងាយរងគ្រោះជាច្រើនក្នុងវដ្តជីវិត, ពិការភាព និងការផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ធ្វើឱ្យស្ថានភាពរបស់ពួកគេកាន់តែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត។ ក្នុងទសវត្សរ៍ចុងក្រោយ ការទទួលមរណភាពដោយសារមេរោគអេដស៍ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ហើយចំណេះដឹងជុំវិញឥរិយាបថបង្ការ និងការការពារបានកើនឡើង ប៉ុន្តែមេរោគអេដស៍ និងជំងឺអេដស៍ នៅតែជាកត្តាជំរុញការរើសអើង និងការផាត់ចេញពីសង្គម។

### ១.២. ទិដ្ឋភាពច្បាប់ និងគោលនយោបាយ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីបន្តប្តេជ្ញាធ្វើស្ថាប័នូបនីយកម្ម និងប្រព័ន្ធនីយកម្មជាជំហានៗ។ ប្រព័ន្ធគាំពារសង្គមត្រូវបានចាត់ទុកថាជាឧបករណ៍គោលនយោបាយមួយ ដើម្បីជំរុញការអភិវឌ្ឍមូលធនមនុស្ស និងកាត់បន្ថយភាពក្រីក្រ ដោយផ្តល់អាទិភាពដល់ការធានាសន្តិសុខប្រាក់ចំណូលសម្រាប់ពលរដ្ឋ ដែលឆ្លុះបញ្ចាំងនៅក្នុងរបៀបវារៈគោលនយោបាយ ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ការឧបត្ថម្ភសាច់ប្រាក់ ជាសមាសធាតុដ៏សំខាន់មួយនៃកិច្ចខិតខំរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ ដូចមានកំណត់ក្នុងផែនការអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ចង្អុលបង្ហាញអំពីអាទិភាពនៃប្រព័ន្ធគាំពារសង្គម និងផ្តោតលើការលើកកម្ពស់ការគាំទ្រ តាមរយៈប្រព័ន្ធជំនួយសង្គម និងការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធសន្តិសុខសង្គម។ ក្របខណ្ឌគោលនយោបាយនេះ កំណត់អាទិភាពជាតិសម្រាប់កិច្ចគាំពារ និងបរិយាបន្នចំពោះប្រជាពលរដ្ឋកម្ពុជា សំដៅពន្លឿនកំណើន និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទាំងមូល។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ចាត់ទុកកិច្ចគាំពារសង្គម ជាការវិនិយោគលើមូលធនមនុស្ស, សមធម៌សង្គម, ឧបករណ៍កសាងភាពធន់ទៅនឹងវិបត្តិ, និងជាការលើកកម្ពស់ការសន្សំ និងវិនិយោគ សម្រាប់គ្រួសារ និងប្រទេសទាំងមូល។ ក្របខណ្ឌគោលនយោបាយនេះ មានចក្ខុវិស័យវែងឆ្ងាយក្នុងការកសាង ប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន ប្រសិទ្ធភាព និងនិរន្តរភាពផ្នែកហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព បង្កើនការអភិវឌ្ឍមូលធនមនុស្ស និងជំរុញកំណើនសេដ្ឋកិច្ច។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ផ្តល់អាទិភាពលើការបង្កើនលទ្ធភាពទទួលបានសន្តិសុខសង្គម និងជំនួយសង្គមសម្រាប់ពលរដ្ឋក្នុងវិស័យសាធារណៈ វិស័យឯកជន និងវិស័យក្រៅប្រព័ន្ធ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យថ្មីសម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជា, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម បានដាក់ចេញនូវផែនការពង្រីកវិសាលភាពជាជំហានៗ។ ទន្ទឹមនេះ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម សង្កត់ធ្ងន់ និងផ្តល់អាទិភាពលើការកែទម្រង់ប្រព័ន្ធគាំពារសង្គម ជាពិសេសផ្តោតការយកចិត្តទុកដាក់លើការគាំពារក្រុមពលរដ្ឋក្រីក្រ និងងាយរងគ្រោះ និងការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ធានាប្រសិទ្ធភាព និងនិរន្តរភាពនៃប្រព័ន្ធគាំពារសង្គម នាពេលអនាគត។ ឯកសារទស្សនាទានស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលបាន

អនុម័តរួច ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំគោលការណ៍ណែនាំស្តីពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងយន្តការអនុវត្ត។

កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងពង្រឹងសមត្ថភាពរបស់គ្រួសារ ក្នុងការវិនិយោគលើមូលធនមនុស្ស និងសម្រេចបាននូវវិបុលភាពយូរអង្វែង តាមរយៈការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមដែលមានស្រាប់ ឬដែលបានគ្រោងទុក ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្ត, ទាញយកអត្ថប្រយោជន៍ពីការគ្របដណ្តប់គ្រប់ជ្រុងជ្រោយលើគ្រួសារក្រីក្រ និងងាយរងគ្រោះ, បង្កើនប្រសិទ្ធភាពចំណាយ, និងកសាងប្រព័ន្ធជំនួយសង្គមប្រកបដោយចីរភាពនៅប្រទេសកម្ពុជា។

## ២. សនិទានភាពក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

ចាប់តាំងពីការដាក់ឱ្យអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ និងការដាក់ឱ្យដំណើរការក្រុមប្រឹក្សាជាតិគាំពារសង្គម, ប្រព័ន្ធគាំពារសង្គមកម្ពុជាបានឈានទៅមុខយ៉ាងឆាប់រហ័ស ដោយមានការវិនិយោគជាយុទ្ធសាស្ត្របន្តបន្ទាប់ ដើម្បីពង្រឹងប្រព័ន្ធនេះ។ ស្របតាមអាទិភាពនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម, រាជរដ្ឋាភិបាលបានផ្តោតលើការបង្កើតទឡ្ហីករណ៍ពាក់ព័ន្ធនឹងសមិទ្ធិលទ្ធភាព ក្នុងការធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គម ក្នុងរយៈពេលខ្លី និងមធ្យម។

ប៉ុន្មានឆ្នាំចុងក្រោយនេះ, រាជរដ្ឋាភិបាលបានវិនិយោគលើគម្រោងសំខាន់ៗមួយចំនួន ក្នុងគោលដៅធ្វើសមាហរណកម្មប្រព័ន្ធគាំពារសង្គម រួមមាន (១) ការធ្វើឱ្យប្រសើរឡើងនូវដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះ (២) ឌីជីថលូបនីយកម្មនៃការបើកផ្តល់អត្ថប្រយោជន៍ និង (៣) ការប្រេបាច់បញ្ចូលគ្នានៃកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់។ ការអភិវឌ្ឍ និងការអនុវត្តការឧបត្ថម្ភសាច់ប្រាក់តាមប្រព័ន្ធឌីជីថលពេញលេញសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារតូច (កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ) មកពីគ្រួសារមានបណ្ណសមធម៌ជាសមិទ្ធផលដ៏សំខាន់មួយសម្រាប់ប្រព័ន្ធគាំពារសង្គម។ ការណ៍នេះ បង្កើតជាមូលដ្ឋានគ្រឹះសម្រាប់កសាងប្រព័ន្ធគាំពារសង្គមមួយដែលជឿនលឿន និងមានលក្ខណៈសមាហរណ៍ ដែលអាចជាឧត្តមានុវត្តន៍សម្រាប់ប្រទេសនានាក្នុងតំបន់។

ស្របតាមការប្តេជ្ញាក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងការសិក្សាសមិទ្ធិលទ្ធភាពនៃក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនៅកម្ពុជា, រាជរដ្ឋាភិបាលបានធ្វើការវិភាគ និងវាយតម្លៃជាប្រព័ន្ធ ដើម្បីស្វែងយល់ពីលទ្ធភាពក្នុងការបង្កើតកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះ។ បន្ទាប់ពីពិចារណាយ៉ាងហ្មត់ចត់ លើការអនុវត្តកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់ និងផ្អែកលើមេរៀនដែលទទួលបានពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានបញ្ជាក់ជាថ្មីអំពីតម្រូវការឱ្យមានដំណើរប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សមាហរណ៍ និងសមហេតុផល សម្រាប់ការរៀបចំយន្តការអនុវត្តកម្មវិធីជំនួយសង្គមនៅប្រទេសកម្ពុជា។

### ២.១. ការបង្កើនប្រសិទ្ធភាព

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ផ្តល់ការឧបត្ថម្ភជាកញ្ចប់ដែលមានលក្ខណៈសមាហរណ៍ ដោយផ្អែកលើប្រព័ន្ធរួមមួយសម្រាប់ការកំណត់អត្តសញ្ញាណ, ការបើកផ្តល់, និងប្រព័ន្ធតាមដាន ដើម្បីផ្តល់អត្ថប្រយោជន៍ជំនួយសង្គមប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ខណៈរក្សាសិទ្ធិបុគ្គលអ្នកទទួលផល ក្នុងកម្រិតមួយដែលអាចធ្វើទៅបាន។ ការធ្វើសមាហរណកម្មមុខងារគាំទ្រ តាមរយៈការសម្រួលវិធានអត្តសញ្ញាណកម្ម ការកំណត់ក្រុមគោលដៅ និងដំណើរការចុះឈ្មោះជាការងារអាទិភាពនៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

លើសពីនេះ ឌីជីថលូបនីយកម្មនៃការបើកផ្តល់សាច់ប្រាក់នឹងកាត់បន្ថយចំណាយរដ្ឋបាល ហើយក៏សម្រេចបាននូវគោលបំណង ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុចំពោះពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងទប់ស្កាត់ភាពបែកខ្ញែក និងត្រួតគ្នា តាមរយៈការបង្កើតប្រតិបត្តិករទោល, ការប្រមូលផ្តុំការគិតគូរគោលនយោបាយ និងការកែលម្អយន្តការសម្របសម្រួលអន្តរវិស័យសម្រាប់ប្រព័ន្ធជំនួយសង្គម។

ស័ក្តិសិទ្ធិភាពនៃប្រតិបត្តិការនឹងត្រូវបានបង្កើន តាមរយៈការធ្វើឱ្យដំណើរការមានភាពសាមញ្ញ ការបន្ស៊ី និងការធ្វើសមាហរណកម្មមុខងាររួម និងការកាត់បន្ថយតម្រូវការធនធានមនុស្ស និងបរិក្ខារូបវន្តក្នុងការអនុវត្តកម្មវិធី តាមរយៈស្វ័យប្រវត្តិកម្មកម្មវិធី។ ទន្ទឹមនេះ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងអនុញ្ញាតឱ្យមានការពង្រឹងក្របខណ្ឌស្ថាប័ន និងហិរញ្ញប្បទានសម្រាប់កម្មវិធីជំនួយសង្គម ហើយនឹងជួយកាត់បន្ថយនូវការរាំងស្ទះផ្នែករដ្ឋបាល និងសម្រួលដល់ការអនុវត្តការបើកផ្តល់។ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានរៀបចំផ្អែកលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័នដែលមានស្រាប់ និងកំពុងដំណើរការកែទម្រង់ ដើម្បីបង្កើនការគ្របដណ្តប់ពេញមួយវដ្តជីវិត និងពង្រឹងការអនុវត្តកម្មវិធីជាតិជំនួយសង្គម។ តាមរយៈការធ្វើសមាហរណកម្មមុខងារ និងមូលដ្ឋានទិន្នន័យរបស់កម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់ និងការធ្វើស្វ័យប្រវត្តិកម្មការបើកផ្តល់អត្ថប្រយោជន៍នឹងបង្កើនប្រសិទ្ធភាពចំណាយ នៃអន្តរាគមន៍ជំនួយសង្គមក៏ដូចជាជួយបង្កើនលទ្ធភាពទទួលបាន និងពង្រីកការគ្របដណ្តប់។

តាមរយៈការបង្កើតកញ្ចប់អត្ថប្រយោជន៍ដែលផ្តល់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះទាំងអស់ និងតាមរយៈការកែលម្អយន្តការអត្តសញ្ញាណកម្ម និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបើកផ្តល់, ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នឹងលើកកម្ពស់ក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នផងដែរ។ កិច្ចការនេះនឹងធ្វើឱ្យប្រព័ន្ធបញ្ជូនបន្តកាន់តែប្រសើរឡើង តាមរយៈការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីធានាថាអ្នកដែលរស់នៅក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ អាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គមនានា។

### ២.២. ការឈានទៅគ្របដណ្តប់ជនងាយរងគ្រោះ តាមរយៈវិធីសាស្ត្រសមាហរណកម្ម

ប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈសមាហរណនឹងគាំពារអ្នកទទួលផលពេញមួយវដ្តជីវិត ចាប់តាំងពីស្ត្រីមានផ្ទៃពោះ និងកុមារតូច រហូតដល់មនុស្សវ័យចាស់ រួមចំណែកការពង្រឹងការអភិវឌ្ឍមូលធនមនុស្ស។ កិច្ចគាំពារសង្គមអនុញ្ញាតឱ្យគ្រួសារអាចវិនិយោគក្នុងរយៈពេលវែងលើការអប់រំ សុខភាព និងអាហារូបត្ថម្ភ ជំរុញជវភាព និងឯករាជ្យភាពនៃសមាជិកគ្រួសារដែលងាយរងគ្រោះ ទន្ទឹមនឹងការកសាងមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ចនាពេលអនាគត។ ប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈសមាហរណ ប្រើប្រាស់វិធីសាស្ត្រពហុវិមាត្រ ដើម្បីដោះស្រាយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច-សង្គម ព្រមទាំងទំនាក់ទំនងនៃភាពងាយរងគ្រោះទាំងនោះ។

វិធីសាស្ត្រសមាហរណកម្មនេះ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ ដើម្បីជួយពលរដ្ឋ ក្នុងការទប់ទល់នឹងវិបត្តិប៉ុណ្ណោះទេ ថែមទាំងអនុញ្ញាតឱ្យគ្រួសារទាំងនោះមានលទ្ធភាពក្នុងការកាត់បន្ថយ និងបង្ការហានិភ័យ ដើម្បីគ្រប់គ្រងភាពងាយរងគ្រោះដែលបង្កដោយគ្រោះអាសន្ន ឱ្យកាន់តែល្អជាងមុន ព្រមទាំងជួយពង្រឹងការអភិវឌ្ឍសង្គមប្រកបដោយបរិយាបន្ន និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានគោលបំណងបង្កើនការទទួលបាន និងវិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម ដើម្បីផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ដល់គ្រួសារងាយរងគ្រោះ។

ផលចំណេញដែលទទួលបានពីស័ក្តិសិទ្ធិភាពនៃការធ្វើសមាហរណកម្ម អាចត្រូវបានប្រើប្រាស់ដើម្បីពង្រីកការគ្របដណ្តប់ និងបង្កើនការទទួលបានអត្ថប្រយោជន៍ជំនួយសង្គម ដែលអនុញ្ញាតឱ្យប្រព័ន្ធនេះឆ្លើយតបនឹងភាពងាយរងគ្រោះពេញមួយវដ្តជីវិត។ ក្នុងន័យនេះ វិធីសាស្ត្រសមាហរណកម្មដែលអនុវត្តដោយក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ឆ្លើយតបផ្ទាល់ទៅនឹងគោលបំណងនៃការរៀបចំកិច្ចគាំពារសង្គមជាប្រព័ន្ធ និងសម្រេចបាននូវគោលដៅក្នុងការបង្កើត "ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ" ដូចបានចង្អុលបង្ហាញក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងដែលដាក់ឱ្យអនុវត្តដោយគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល នេះ។

## ២.៣. មេរៀន និងបទពិសោធន៍ពីការឆ្លើយតបនឹងជំងឺកូវីដ-១៩

ជំងឺកូវីដ-១៩ បានបង្កបញ្ហាប្រឈមចំពោះប្រព័ន្ធគាំពារសង្គមនៅបណ្តាប្រទេសនានាទូទាំងពិភពលោក និងបានធ្វើឱ្យរដ្ឋាភិបាលនានាយល់ដឹងអំពីអត្ថប្រយោជន៍ដ៏សំខាន់របស់ប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សមាហរ័ណ និងស្វ័យប្រវត្តិ។ ការឆ្លើយតបនឹងជំងឺកូវីដ-១៩ របស់ប្រទេសកម្ពុជា ទទួលបានការកោតសរសើរជាសកល ហើយការឆ្លើយតបនេះអាចអនុវត្តបានតាមរយៈការវិនិយោគរបស់រាជរដ្ឋាភិបាលលើប្រព័ន្ធគាំពារសង្គមជាជំហានៗកន្លងមក។ ការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គមបានផ្តល់ភាពងាយស្រួល និងឆាប់រហ័សដល់ការសម្រេចចិត្តផ្នែកគោលនយោបាយលើការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់។ យន្តការនានា ដូចជាយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ អាចផ្តល់លទ្ធភាពក្នុងការពង្រីកវិសាលភាពគ្របដណ្តប់ឆាប់រហ័សដល់គ្រួសារគោលដៅ ដែលត្រូវការជំនួយជាចាំបាច់ក្នុងវិបត្តិជំងឺកូវីដ-១៩។

ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ រួមមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន យន្តការចុះឈ្មោះ និងការបើកផ្តល់ប្រាក់ឧបត្ថម្ភ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់បន្ទាន់ក្នុងទំហំ និងល្បឿន ដែលមិនធ្លាប់មានពីមុនមក។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ផ្តល់នូវអភិក្រមសម្លឹងឆ្ពោះទៅមុខរបស់រាជរដ្ឋាភិបាល ដោយប្រើប្រាស់យន្តការបើកផ្តល់ស្វ័យប្រវត្តិពេញលេញ ចាប់តាំងពីការចុះឈ្មោះ រហូតដល់ការតាមដាន និងវាយតម្លៃ តាមរយៈការតភ្ជាប់ជាមួយប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, ប្រព័ន្ធបើកផ្តល់ឌីជីថល, និងការប្រើប្រាស់រចនាសម្ព័ន្ធឃុំសង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ សម្រាប់ការផ្សព្វផ្សាយ

ព័ត៌មាន ការចុះឈ្មោះ និងការដោះស្រាយបណ្ដឹងតវ៉ា ដែលបង្ហាញពីភាពជោគជ័យយ៉ាងខ្លាំង ខណៈប្រើប្រាស់កិច្ចសហប្រតិបត្តិការអន្តរវិស័យសម្រាប់ការអនុវត្តកម្មវិធី។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ និងការប្រើប្រាស់យន្តការអនុវត្ត រួមជាមួយនឹងការតភ្ជាប់ទៅនឹងយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ ដើម្បីឆ្លើយតបជាបន្ទាន់ ក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ-១៩ បានបង្ហាញនូវសក្ដានុពលនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម និងលទ្ធភាពក្នុងការអនុវត្តយន្តការទាំងនេះ ដែលមិនត្រឹមតែពង្រឹងប្រព័ន្ធគាំពារសង្គមប៉ុណ្ណោះទេ ថែមទាំងរួមចំណែកដល់ការឆ្លើយតបនឹងគ្រោះអាសន្នកាន់តែប្រសើរឡើងផងដែរ។ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងបន្តជួយគាំទ្របុគ្គល និងគ្រួសារក្រីក្រ និង ងាយរងគ្រោះ នៅពេលដែលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់។

## ៣. គោលបំណង

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានគោលដៅបង្កើតប្រព័ន្ធជំនួយសង្គម ដែលអាចឆ្លើយតបបានគ្រប់ជ្រុងជ្រោយទៅនឹងតម្រូវការរបស់គ្រួសារក្រីក្រ និងសមាជិកដែលមានភាពងាយរងគ្រោះ ចាប់តាំងពីពេលចាប់កំណើត រហូតដល់មរណភាព ដែលនឹងជួយពង្រឹងស្ថានភាពគ្រួសារ, កសាងសង្គមដែលមានភាពធន់ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន។

ដើម្បីសម្រេចបានចក្ខុវិស័យនេះ, ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារផ្ដោតលើការបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាពប្រតិបត្តិការ, និងប្រសិទ្ធភាពចំណាយនៃការផ្តល់ជំនួយសង្គម ដែលឆ្លើយតបនឹងតម្រូវការរបស់បុគ្គលក្នុងមួយវដ្តជីវិត ហើយផ្តល់ដំណោះស្រាយគ្រប់ជ្រុងជ្រោយចំពោះហានិភ័យ និងភាពងាយរងគ្រោះរបស់ពួកគេ។ ការរៀបចំក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានគោលបំណងផ្តល់នូវការគាំទ្ររួម និងគ្រប់ជ្រុងជ្រោយបន្ថែមទៀតដល់គ្រួសារ និងបុគ្គលងាយរងគ្រោះ តាមរយៈការធ្វើឱ្យដំណើរការគ្រប់គ្រងការអនុវត្តកម្មវិធីមានភាពសាមញ្ញ ការសម្រួលដល់ការទទួលផល ការបន្ថែមលក្ខខណ្ឌទទួលផល និងការធ្វើឱ្យប្រសើរឡើងនូវយន្តការកំណត់ក្រុមគោលដៅដែលត្រូវទទួលផល ជាមួយនឹងគោលបំណងជាក់លាក់ចំនួន៥ រួមមាន៖

### ១) ផ្តល់អត្ថប្រយោជន៍ជំនួយសង្គមគ្រប់ជ្រុងជ្រោយ និងក្នុងទំហំសមរម្យដែលគ្របដណ្តប់បុគ្គលក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ ពេញវដ្តជីវិត

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវគ្របដណ្តប់គ្រប់ជ្រុងជ្រោយលើបុគ្គលនីមួយៗក្នុងវដ្តជីវិត តាមរយៈសមាហរណកម្មប្រតិបត្តិការឧបត្ថម្ភសាច់ប្រាក់ សំដៅកាត់បន្ថយភាពក្រីក្រ, ភាពងាយរងគ្រោះរបស់ពលរដ្ឋ និងលើកកម្ពស់មូលធនមនុស្ស។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព, និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា ត្រូវធ្វើសមាហរណកម្មទៅក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ហើយមានការផ្តល់ប្រាក់ឧបត្ថម្ភគោលសម្រាប់គ្រួសារ និងការគិតគូរបន្ថែមដល់ភាពងាយរងគ្រោះដោយសារមេរោគ/ជំងឺអេដស៍ ក្នុងកញ្ចប់គ្រួសារនេះ ផងដែរ។ កម្មវិធីនីមួយៗក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានបង្កើតឡើងផ្អែកលើគោលការណ៍មិនរើសអើង និងមានគោលបំណងដោះស្រាយវិសមភាពនានា។ ក្នុងន័យនេះ តាមរយៈការផ្តល់អត្ថប្រយោជន៍ជំនួយសង្គមដល់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះទាំងអស់ ដោយមិនគិតពីស្ថានភាពផ្ទុកមេរោគអេដស៍, ភេទ, ឬជាតិពន្ធរបស់ពួកគេ, ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះសំដៅដោះស្រាយកត្តាជំរុញចម្បងនៃហានិភ័យមេរោគ កង្វះប្រាក់ចំណូល កម្រិតអប់រំទាប និងឥរិយាបថក្នុងការស្វែងរក និងប្រើប្រាស់សេវាសុខភាព រួមទាំងគ្របដណ្តប់លើក្រុមអ្នកដែលមានប្រាក់ចំណូលទាបជាងបន្ទាត់នៃភាពក្រីក្រ យុវជន កុមារី ស្ត្រី ស្ត្រីមានផ្ទៃពោះ ជនមានពិការភាព និងជនចាស់ជរាផងដែរ។

**រូបភាពទី ១៖ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**

<table>
<tr><td>កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ</td><td>កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា (ច្របាច់បញ្ចូលទៅជាកម្មវិធីអាហារូបករណ៍តែមួយដើម្បីសម្រួលដំណើរការរដ្ឋបាល)</td><td>កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព (កែសម្រួលពីរបបគោលនយោបាយចំពោះជនពិការក្រីក្រតាមសហគមន៍)</td><td>កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា</td></tr>
<tr><td colspan="4">ការផ្តល់ប្រាក់ឧបត្ថម្ភគោលសម្រាប់គ្រួសារ និងការគិតគូពីភាពងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ យេនឌ័រ និងពិការភាព</td></tr>
</table>

ដើម្បីសម្រេចគោលបំណងនេះ, រាជរដ្ឋាភិបាលនឹង៖ ១)អនុវត្តកម្មវិធីទាំងបួននេះក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារតែមួយ ជាមួយនឹងសក្ដានុពលក្នុងការពង្រីក និងបំពេញបន្ថែមតាមការចាំបាច់ ដើម្បីបំពេញតម្រូវការដែលកំពុងកើតមាន និងដោះស្រាយភាពងាយរងគ្រោះថ្មីៗ, ២)ពង្រីកប្រព័ន្ធជំនួយសង្គមជាជំហានៗ ដោយផ្អែកលើលំហថវិកាជាតិដែលមាន ដើម្បីកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះសម្រាប់មនុស្សគ្រប់វ័យ តាំងពីពេលចាប់កំណើត រហូតដល់មរណៈ, និង ៣) ធានាថាដំណើរការចុះឈ្មោះ និងដំណើរការបើកផ្ដល់ បូកបញ្ចូលបុគ្គលរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងជនមានពិការភាព។

**២) បង្កើនលទ្ធភាពទទួលបានអត្ថប្រយោជន៍ជំនួយសង្គម និងពង្រីកវិសាលភាពគ្របដណ្ដប់**

ការកែលម្អយន្តការកំណត់ក្រុមគោលដៅ ក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវមានការគាំទ្រពីយន្តការអត្តសញ្ញាណកម្ម និងយន្តការកំណត់ក្រុមគោលដៅ ដែលត្រូវបានកែលម្អជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យយន្តការទាំងនេះមានលក្ខណៈសាមញ្ញ, បរិយាបន្ន, និងបត់បែនជាងមុន ដោយធ្វើការកែសម្រួលលក្ខណវិនិច្ឆ័យ។ យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះនឹងរួមបញ្ចូលពលរដ្ឋងាយរងហានិភ័យក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រផងដែរ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹង៖ ១) ពិនិត្យ និងកែលម្អយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយធ្វើការវាយតម្លៃលើវិធីសាស្ត្រកំណត់អត្តសញ្ញាណ និងអភិវឌ្ឍឆ្ពោះទៅវិធីសាស្ត្រវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះ ដើម្បីគ្របដណ្ដប់គ្រួសារងាយរងគ្រោះឱ្យកាន់តែប្រសើរឡើង, ២) ពិនិត្យលើការធ្វើតេស្តមធ្យមភាគតំណាង (Proxy Means Testing) ដែលអនុវត្តដោយយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីស្វែងរកទស្សនាទាននៃប្រភេទភាពងាយរងគ្រោះផ្សេងៗ សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងងាយរងគ្រោះ ប្រកបដោយបរិយាបន្ន, ៣) ពង្រីកយន្តការអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ដើម្បីកំណត់អត្តសញ្ញាណអ្នកទទួលផល ក្រោមកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព, និង ៤) ការពារឯកជនភាពរបស់បុគ្គលរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងពិការភាព ដោយធ្វើមជ្ឈការការបញ្ជាក់សិទ្ធិទទួលផលរបស់ពួកគាត់។

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នឹងអនុញ្ញាតឱ្យគ្រួសារគោលដៅបន្តទទួលបានអត្ថប្រយោជន៍ពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀតដោយស្វ័យប្រវត្តិ។ គ្រួសារដែលមានបណ្ណសមធម៌ ត្រូវចុះឈ្មោះជាមុនដើម្បីទទួលបានអត្ថប្រយោជន៍។ ការចុះឈ្មោះក្នុងកម្មវិធីនឹងធ្វើឡើងបន្ទាប់ពីមានភស្តុតាងបញ្ជាក់អំពីស្ថានភាពបុគ្គល នៅក្នុងក្រុមប្រជាសាស្ត្រ ឬក្រុមគោលដៅណាមួយ (ឧទាហរណ៍៖ ឯកសារបញ្ជាក់អំពីការពរពោះ, លិខិតបញ្ជាក់ពីការចុះឈ្មោះចូលរៀន, ឬបណ្ណសម្គាល់ជនមានពិការភាព ជាដើម)។ នៅពេលបានចុះឈ្មោះក្នុងកម្មវិធីណាមួយរួចហើយ, ក្រុមគោលដៅនោះនឹងទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធីផ្សេងៗដោយស្វ័យប្រវត្តិ (ផ្អែកលើអាយុ ឬដំណាក់កាលនៃវដ្តជីវិត) ដោយគ្រាន់តែតម្រូវឱ្យបញ្ជាក់ពីការអនុវត្តលក្ខខណ្ឌ ក្នុងករណីកម្មវិធីតម្រូវឱ្យមាន។

**៣) ពង្រឹងយន្តការស្ថាប័នសម្រាប់ផ្ដល់អត្ថប្រយោជន៍ជំនួយសង្គម**

កម្មវិធីជាតិជំនួយសង្គម ត្រូវបានអនុវត្តដោយក្រសួង-ស្ថាប័នជាច្រើន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចផ្សេងៗគ្នា។ ការផ្ដល់កិច្ចគាំពារសង្គមប្រកបដោយចីរភាព តម្រូវឱ្យ

មានការបង្កើតប្រព័ន្ធ, រចនាសម្ព័ន្ធ និងការកសាងសមត្ថភាពដល់មន្ត្រីអនុវត្តកម្មវិធី និងអ្នកផ្តល់សេវាផ្សេងៗទៀត។ ដើម្បីពង្រឹងយន្តការស្ថាប័នសម្រាប់ការអនុវត្តកម្មវិធីជំនួយសង្គម, រាជរដ្ឋាភិបាលបានបង្កើតមូលនិធិជាតិជំនួយសង្គម ដើម្បីដឹកនាំ និងអនុវត្ត។ លើសពីនេះ, រាជរដ្ឋាភិបាលនឹងអនុវត្តការងារអាទិភាព ដូចខាងក្រោម៖

- បង្កើត និងពង្រឹងយន្តការសម្របសម្រួលសម្រាប់កិច្ចគាំពារសង្គមនៅថ្នាក់ក្រោមជាតិ
- ផ្តល់ការបណ្តុះបណ្តាលទៅតាមគោលដៅ និងគោលបំណងជាក់លាក់ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីប្រព័ន្ធជំនួយសង្គម, ដំណើរការពាក់ព័ន្ធ, តួនាទីនិងភារកិច្ច
- ពង្រីកប្រព័ន្ធតាមដាន និងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាព ស្របតាមក្របខណ្ឌតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមដែលមានស្រាប់។ ការណ៍នេះ តម្រូវឱ្យធ្វើសមាហរណកម្មក្របខណ្ឌតាមដាន និងវាយតម្លៃសម្រាប់កម្មវិធីទាំងអស់ ដោយផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូររបស់កម្មវិធី និងរួមបញ្ចូលទាំងការវាយតម្លៃដំណើរការ និងសូចនាករ លទ្ធផលចុងក្រោយ
- ចូលរួមពង្រឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងតភ្ជាប់ការចុះបញ្ជីអត្រានុកូលដ្ឋានជាមួយប្រព័ន្ធបច្ចេកវិទ្យា គ្រប់គ្រងព័ត៌មានរបស់ប្រព័ន្ធគាំពារសង្គម
- បង្កើតម៉ូឌុលសម្រាប់កម្មវិធីជំនួយសង្គមនីមួយៗ ដើម្បីបង្កើតប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរួម
- ពង្រឹងសមត្ថភាពបច្ចេកទេស និងធនធានមនុស្ស សម្រាប់ការអនុវត្តកម្មវិធីជំនួយសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ការបញ្ជ្រាបការយល់ដឹងដល់សហគមន៍, ការកំណត់ក្រុមគោលដៅ, ការចុះឈ្មោះ, ការបញ្ជាក់ការអនុវត្តលក្ខខណ្ឌ, ការបើកផ្តល់សាច់ប្រាក់, និងការគ្រប់គ្រងបណ្តឹងត៉វា តាមប្រព័ន្ធឌីជីថល
- បង្កើតយន្តការផ្តល់ហិរញ្ញប្បទានរយៈពេលវែងសម្រាប់ប្រព័ន្ធគាំពារសង្គម
- រៀបចំក្រុមកម្លាំងសេវាសង្គម(វិជ្ជាជីវៈ និងពាក់កណ្តាលវិជ្ជាជីវៈ) ដែលអាចគាំទ្រប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់កម្មវិធី ព្រមទាំងបង្កើនការគ្របដណ្តប់ និងប្រសិទ្ធភាពនៃជំនួយសង្គម។

### ៤) បង្កើតមុខងារនៃប្រព័ន្ធរួម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការប្រព័ន្ធជំនួយសង្គម

កម្មវិធីជាតិជំនួយសង្គម ជាពិសេសកម្មវិធីឧបត្ថម្ភសាច់ប្រាក់ អាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីមុខងារនៃប្រព័ន្ធរួម។ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដែលមានលក្ខណៈសមាហរណៈ នាំមកនូវការពង្រីកវិសាលភាពគ្របដណ្តប់ ហើយការប្រើប្រាស់ប្រព័ន្ធបើកផ្តល់ និងយន្តការអនុវត្តកម្មវិធីរួម អនុញ្ញាតឱ្យមានសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale) និងធ្វើឱ្យមានប្រសិទ្ធភាពចំណាយ។ ជាមួយគ្នានេះ ការប្រើប្រាស់ដំណើរការរួម និងប្រព័ន្ធឌីជីថលក្នុងវដ្តកម្មវិធីទាំងមូល ជួយកាត់បន្ថយបន្ទុករដ្ឋបាលនៃដំណើរការកម្មវិធីនានា ដែលមានភាពស្មុគស្មាញ និងរាយប៉ាយ និងជួយកាត់បន្ថយការងារក្រដាសស្នាម ព្រមទាំងធ្វើឱ្យប្រតិបត្តិការ និងចំណាយរបស់កម្មវិធី

មានប្រសិទ្ធភាពជាងមុន។ ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលនឹងអនុវត្តការងារអាទិភាព ដូចខាងក្រោម៖

- បង្កើតទម្រង់, ឧបករណ៍, និងដំណើរការថ្នាលឌីជីថលរួម សម្រាប់ការផ្ទៀងផ្ទាត់ក្នុងកម្មវិធីជាតិជំនួយសង្គមទាំងអស់
- បង្កើតម៉ូឌុលនៃប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន សម្រាប់កម្មវិធីទាំងអស់ ដោយផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ
- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានដែលមានលក្ខណៈសមាហរណ៍ សម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលប្រមូលផ្តុំទិន្នន័យពីម៉ូឌុលនៃកម្មវិធីនានា បង្កើត និងអនុវត្តម៉ូឌុលរួម ព្រមទាំងអនុញ្ញាតដល់សមាហរណកម្មម៉ូឌុលកម្មវិធី ដើម្បីឱ្យដំណើរការកម្មវិធីមានភាពសាមញ្ញ និងធ្វើឱ្យយន្តការ តាមដាន និងវាយតម្លៃប្រសើរឡើង
- ធានាបាននូវតំណភ្ជាប់នៃប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងធ្វើសមាហរណកម្មជាមួយនឹងមូលដ្ឋានទិន្នន័យពាក់ព័ន្ធផ្សេងទៀត ដូចជាថ្នាលឌីជីថលនៃយន្តការតាមដាន និងវាយតម្លៃមូលដ្ឋាន ទិន្នន័យនៃប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព និងប្រព័ន្ធសុខដុមនីយកម្មនៃការចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម
- ធ្វើសមាហរណ៍រាល់ដំណើរការកម្មវិធីទាំងអស់ទៅក្នុងបណ្តាញ ឬប្រព័ន្ធតែមួយ ស្របតាមគោលបំណងនៃកម្មវិធី
- បង្កើតក្របខណ្ឌហិរញ្ញប្បទានរួម និងយន្តការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់អត្ថប្រយោជន៍ជំនួយសង្គមទាំងអស់
- ធ្វើពិពិធកម្មប្រព័ន្ធបើកផ្តល់ឌីជីថលរួម ដើម្បីបំពេញតម្រូវការរបស់អ្នកទទួលផល។

**៥) តម្រង់ទិសសម្រាប់ការរៀបចំប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់ រវាងប្រព័ន្ធជំនួយសង្គម សេវាសង្គមកិច្ច និងសន្តិសុខសង្គម ព្រមទាំងកម្មវិធីបំពេញបន្ថែមដែលមានស្រាប់ផ្សេងទៀត**

ការបំពេញបន្ថែមប្រព័ន្ធជំនួយសង្គមជាមួយនឹងសេវាសង្គមកិច្ច ត្រូវបានទទួលស្គាល់ថានឹងបង្កើនផលវិជ្ជមាននៃអត្ថប្រយោជន៍ជំនួយសង្គម។ តាមរយៈការផ្តល់នូវការគាំទ្រពេញលេញ និងការដោះស្រាយឧបសគ្គមិនមែនរូបិយវត្ថុ ការតភ្ជាប់ប្រព័ន្ធជំនួយសង្គម ជាមួយនឹងសេវាសង្គមកិច្ច និងកម្មវិធីបំពេញបន្ថែម អាចធ្វើឱ្យលទ្ធផលចុងក្រោយនៃជំនួយសង្គមកាន់តែប្រសើរឡើង ដែលនឹងនាំឱ្យផលធៀបរវាងអត្ថប្រយោជន៍ និងចំណាយ (Benefit-Cost Ratio) មានកម្រិតកាន់តែខ្ពស់។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងអនុវត្តការងារអាទិភាព ដូចខាងក្រោម៖

- លើកកម្ពស់យន្តការឆ្លើយតបតាមសហគមន៍ ដើម្បីគាំពារជនងាយរងគ្រោះ តាមរយៈការបញ្ជូនបន្តទៅទទួលសេវាគាំទ្រនានា។ ការបណ្តុះបណ្តាល និងការផ្តល់សិទ្ធិអំណាចដល់តួអង្គនៅកម្រិតសហគមន៍ (សាលារៀន មណ្ឌលសុខភាព អ្នកផ្តល់សេវាផ្សេងៗ) ដើម្បីជួយសម្រួលដល់ជនងាយរងគ្រោះក្នុងការទទួលបានជំនួយសង្គម និងបញ្ជូនបន្តទៅទទួលសេវាសង្គមកិច្ចផ្សេងទៀត អាចបង្កើនរូបភាព និងការយល់ដឹងអំពីក្របខណ្ឌ

កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ព្រមទាំងបង្កើនការទទួលយកអត្ថប្រយោជន៍ និងកាត់បន្ថយការផាត់ចេញពីកម្មវិធី តាមរយៈការរៀបចំកិច្ចប្រជុំ តាមកាលកំណត់

- ពង្រីកវិសាលភាព និងការគ្របដណ្តប់នៃសេវាថែទាំ សេវាគាំទ្រ និងសេវាការពារ ដែលមានស្រាប់ ហើយតភ្ជាប់សេវាទាំងនេះជាមួយប្រព័ន្ធជំនួយសង្គម
- លើកកម្ពស់ការបញ្ជូនបន្តទៅកាន់កម្មវិធីបំពេញបន្ថែមសំខាន់ៗ ដូចជារបបសន្តិសុខសង្គម មូលនិធិសមធម៌សុខាភិបាល កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងសេវាសង្គមកិច្ច ជាដើម
- លើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការផ្តល់សេវាថែទាំសង្គម សេវាគាំទ្រ និងសេវាការពារ និងកម្មវិធីបំពេញបន្ថែម
- កសាងសមត្ថភាពរបស់អ្នកផ្តល់សេវាថែទាំសង្គម និងអ្នកផ្តល់សេវាគាំទ្រសង្គម។

## ៤. ទ្រឹស្តីនៃការផ្លាស់ប្តូរ

**រូបភាពទី២** ខាងក្រោម បង្ហាញពីទ្រឹស្តីនៃការផ្លាស់ប្តូរកម្រិតខ្ពស់របស់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដោយបញ្ជាក់ពីរបៀបដែលសមាសធាតុនីមួយៗគាំទ្រដល់គ្រួសារគោលដៅឱ្យកាន់តែមានភាពធន់ទៅនឹងវិបត្តិ ក៏ដូចជាបង្កើនផលិតភាពរបស់គ្រួសារ ដោយការប្រមូលផ្តុំមូលធនមនុស្ស តាមរយៈការទទួលបានការអប់រំ ការថែទាំសុខភាព និងអាហារូបត្ថម្ភ។

**រូបភាពទី២៖ ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ**



## ៥. យន្តការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារផ្តល់កញ្ចប់ជំនួយសង្គមចាំបាច់សម្រាប់គាំពារគ្រួសារក្រីក្រ និងងាយរងគ្រោះពេញវដ្តជីវិត។ នៅដំណាក់កាលដំបូង, ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារត្រូវធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គម ដែលមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ចំនួន៤ ដោយពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលនូវអត្ថប្រយោជន៍ផ្សេងទៀតតាមការចាំបាច់នៅដំណាក់កាលបន្ទាប់។ កម្មវិធីជាតិជំនួយសង្គមទាំង៤ ដែលត្រូវសមាហរណកម្មក្រោមក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ រួមមាន៖ ១)កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, ២)កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា, ៣)កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព, និង ៤)កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា។

បន្ថែមលើនេះ, ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនេះក៏ផ្តល់នូវការឧបត្ថម្ភគោលជូនគ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ និងគិតគូរដល់សមាជិកគ្រួសារដែលរស់នៅជាមួយមេរោគ/ជំងឺអេដស៍ ផងដែរ។

### ៥.១. ការកំណត់ក្រុមគោលដៅ និងការកំណត់អត្តសញ្ញាណ

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ប្រើប្រាស់យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងការកំណត់ក្រុមគោលដៅ។ យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះនេះ ត្រូវបានកែលម្អជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យការកំណត់ក្រុមគោលដៅកាន់តែមានភាពសាមញ្ញ និងមានបរិយាបន្នជាងមុន។

### ៥.២. សិទ្ធិទទួលបានអត្ថប្រយោជន៍ និងលក្ខខណ្ឌនៃការបញ្ចូលក្នុងកម្មវិធី

សិទ្ធិទទួលបានអត្ថប្រយោជន៍របស់កម្មវិធី ត្រូវអនុវត្តចំពោះគ្រួសារដែលបានកំណត់អត្តសញ្ញាណ និងមានស្ថានភាពជាគ្រួសារកម្រិតភាពក្រ១ ឬ ក្រ២ តាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំនៅពេលស្នើបញ្ចូលក្នុងកម្មវិធី និងសមាជិកគ្រួសារដែលមានលក្ខខណ្ឌប្រជាសាស្ត្រដូចខាងក្រោម៖

- ស្ត្រីមានផ្ទៃពោះ ឬកុមារមានអាយុពី០-២ឆ្នាំ នៅថ្ងៃ ឬក្រោយកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការកម្មវិធី (ជាមួយនឹងលទ្ធភាពពង្រីកវិសាលភាពគ្របដណ្តប់ជាជំហាន ដល់កុមារដែលមានអាយុ ចាប់ពី៣-៥ឆ្នាំ ទៅតាមលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ)
- សិស្សបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ឬមធ្យមសិក្សាចំណេះដឹងទូទៅរហូតដល់ថ្នាក់ទី១២
- អ្នកដែលត្រូវបានបញ្ជាក់ថាមានពិការភាពតាមរយៈយន្តការអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន (អ្នកមានបណ្ណសម្គាល់ជនមានពិការភាព)
- អ្នកដែលមានអាយុចាប់ពី ៦០ឆ្នាំ ឡើង
- អ្នកមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

ចំពោះគ្រួសារ ដែលត្រូវបានកំណត់ជាគ្រួសារមានស្ថានភាពក្រីក្រ កម្រិតក្រ១ ឬក្រ២ ដែលមានសមាជិកគ្រួសារជាកុមារតូច, កុមារដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ឬមធ្យមសិក្សា

ចំណេះដឹងទូទៅ, ជនមានពិការភាព, និងជនចាស់ជរាដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ឬអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នឹងទទួលបានអត្ថប្រយោជន៍ទាំងអស់។

ក្នុងករណីដែលគ្រួសារនៅមានសិទ្ធិទទួលបានអត្ថប្រយោជន៍តាមលក្ខណៈវិនិច្ឆ័យ នៃការកំណត់ក្រុមគោលដៅ សមាជិកគ្រួសារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលបានការឧបត្ថម្ភសាច់ប្រាក់, អាចចុះឈ្មោះ, ទទួលបានអត្ថប្រយោជន៍ទាំងនេះយ៉ាងងាយស្រួល និងបន្តដោយស្វ័យប្រវត្តិពីកម្មវិធីមួយ ទៅកម្មវិធីបន្ទាប់ទៅតាមវ័យរបស់ពួកគេ។

## ៥.៣. អត្ថប្រយោជន៍ លក្ខខណ្ឌ និងការបើកផ្តល់

រាជរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់ជម្រើសវិធីសាស្ត្របើកផ្តល់អត្ថប្រយោជន៍ ដូចខាងក្រោម៖

**ជម្រើសបច្ចុប្បន្ន - គណនីទោលគ្រួសារ**

គណនីទោលគ្រួសារ ដូចការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងកូវីដ-១៩ បច្ចុប្បន្ន នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់អត្ថប្រយោជន៍ក្រោមក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ។

**ជម្រើសជំនួស - គណនីបុគ្គល**

ការវាយតម្លៃលើការប្រើប្រាស់គណនីទោលគ្រួសារ ដែលជាជម្រើសដើមខាងលើ នឹងត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទសមស្របណាមួយ ដើម្បីពិនិត្យមើលផលប៉ះពាល់លើសិទ្ធិបុគ្គល និងបុគ្គលដែលជាជនងាយរងគ្រោះក្នុងគ្រួសារ។ ការវាយតម្លៃនេះ នឹងត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជាតិគាំពារសង្គម និងមានការគាំទ្រពីភាគីពាក់ព័ន្ធ។ ករណីការវាយតម្លៃបង្ហាញថា មានតម្រូវការក្នុងការកែប្រែវិធីសាស្ត្របើកផ្តល់, ជម្រើសគណនីបុគ្គលនឹងត្រូវបានពិនិត្យលទ្ធភាពដាក់ឱ្យប្រើប្រាស់ ឬផ្តល់ជាជម្រើសសម្រាប់គ្រួសារ សំដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងធ្វើឱ្យជីវភាពផ្ទៃក្នុងគ្រួសារសម្រាប់បុគ្គលងាយរងគ្រោះមានភាពប្រសើរឡើង។

តារាងខាងក្រោមបង្ហាញអំពីកម្រិតអត្ថប្រយោជន៍ចំនួនលើក និងលក្ខខណ្ឌរបស់កម្មវិធីនីមួយៗក្រោមក្របខណ្ឌក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ កម្រិតអត្ថប្រយោជន៍ទាំងនេះនឹងចាប់ផ្តើមជាមួយនឹងទំហំដែលបានកំណត់ ដូចមានក្នុងតារាងខាងក្រោម ហើយនឹងត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ អាស្រ័យលើស្ថានការណ៍វិវត្តនៃសង្គម-សេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ។

**តារាងទី១ ៖ កម្រិតអត្ថប្រយោជន៍ និងចំនួនលើកនៃការបើកផ្តល់ និងលក្ខខណ្ឌ**

| ប្រភេទ អត្ថប្រយោជន៍ | លក្ខខណ្ឌ | កាលវិភាគបើកផ្តល់ | ចំនួនលើក | ចំនួនសាច់ប្រាក់ត្រូវផ្ទេរក្នុងមួយលើក (គិតជារៀល) |
|---|---|---|---|---|
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ | ប្រាក់ឧបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះដែលភ្ជាប់លក្ខខណ្ឌពិនិត្យផ្ទៃពោះចំនួន៤ដង មុនពេលសម្រាល | យ៉ាងតិច ១២សប្តាហ៍ ២០-២៤សប្តាហ៍ ៣០-៣២សប្តាហ៍ និង៣៦-៣៨សប្តាហ៍ | ៤ដងក្នុងរយៈពេល ២៦សប្តាហ៍ | ៨០ ០០០ |
| | ប្រាក់ឧបត្ថម្ភសម្រាប់ការសម្រាលកូន | ពេលសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ | មួយលើក | ៤០០ ០០០ បូក ២០០ ០០០ សម្រាប់កូនភ្លោះម្នាក់បន្ថែម |

| | | | | |
|---|---|---|---|---|
| | ប្រាក់ឧបត្ថម្ភក្រោយសម្រាលដែលភ្ជាប់លក្ខខណ្ឌពិនិត្យសុខភាពចំនួន៣ដង | ៧ថ្ងៃ១៤ថ្ងៃ និង១,៥ខែ បន្ទាប់ពីសម្រាល (ទាំងម្តាយ និងកូន) | ៣ដង ក្នុងរយៈពេល ១,៥ខែ | ៨០ ០០០ |
| | ប្រាក់ឧបត្ថម្ភសម្រាប់កុមារដែលភ្ជាប់លក្ខខណ្ឌពិនិត្យសុខភាព និងចាក់វ៉ាក់សាំង និងថ្នាំបង្ការ | ស្របតាមកាលវិភាគចាក់ថ្នាំបង្ការសម្រាប់កូន (រហូតដល់អាយុ១៨ខែ) | ៧ដង ក្នុងរយៈពេល ១៥,៥ ខែ | ៨០ ០០០ |
| ការឧបត្ថម្ភកុមារចាប់ពីអាយុ៣ឆ្នាំដល់អាយុចូលរៀន | លទ្ធភាពពង្រីកវិសាលភាពគ្រប់ដណ្តប់នៃការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារតូចដល់កុមារអាយុពី៣-៥ឆ្នាំ (រហូតដល់ពួកគេចុះឈ្មោះចូលរៀននៅបឋមសិក្សា) ផ្អែកលើលំហថវិកាជាតិដែលមានសម្រាប់ការពង្រីកវិសាលភាពបែបនេះ | | | |
| កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា (ថ្នាក់ទី១ ដល់ថ្នាក់ទី១២) | កុមារបានចូលរៀននៅបឋមសិក្សា (ថ្នាក់ទី១-៦) | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ២០ ០០០ |
| | កុមារបានចូលរៀននៅមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ២០ ០០០ |
| | កុមារបានចូលរៀននៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ៣០ ០០០ |
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ៦០ឆ្នាំឡើង) | ជនចាស់ជរាដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ២៨ ០០០ |
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព | ជនមានពិការភាព (មានបណ្ណសម្គាល់) | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ២៨ ០០០ |
| ការឧបត្ថម្ភជូនសមាជិកគ្រួសារមានផ្ទុកមេរោគ/ជំងឺអេដស៍ | គ្រួសារមានបណ្ណសមធម៌ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ២៨ ០០០ |
| ការឧបត្ថម្ភគោល | គ្រួសារមានបណ្ណសមធម៌ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ១២ដង/ឆ្នាំ (ប្រចាំខែ) | ៣៤ ០០០ |

សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ការបើកផ្តល់សាច់ប្រាក់ចំនួន ១៥លើក ត្រូវបានភ្ជាប់នឹងលក្ខខណ្ឌនៃការពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ និងការពិនិត្យសុខភាពក្រោយសម្រាល ក៏ដូចជាការចាក់ថ្នាំបង្ការដល់កុមារតាមកាលបរិច្ឆេទដូចមានបញ្ជាក់ ក្នុងតារាងខាងក្រោម៖

**តារាងទី២៖ ទង្គនៃការបើកផ្តល់ប្រាក់ឧបត្ថម្ភ ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ**

| ដំណាក់កាល | ការអនុវត្តលក្ខខណ្ឌ | ពេលវេលា | ប្រាក់ឧបត្ថម្ភ |
|---|---|---|---|
| ដំណាក់កាលទី១ | ពិនិត្យផ្ទៃពោះលើកទី១ | គភ៌អាយុតិចជាង១២សប្តាហ៍ | ៨០ ០០០ រៀល |
| | ពិនិត្យផ្ទៃពោះលើកទី២ | គភ៌អាយុតិចជាង២០-២៤សប្តាហ៍ | ៨០ ០០០ រៀល |
| | ពិនិត្យផ្ទៃពោះលើកទី៣ | គភ៌អាយុតិចជាង៣០-៣២សប្តាហ៍ | ៨០ ០០០ រៀល |
| | ពិនិត្យផ្ទៃពោះលើកទី៤ | គភ៌អាយុតិចជាង៣៦-៣៨សប្តាហ៍ | ៨០ ០០០ រៀល |
| ដំណាក់កាលទី២ | សម្រាលកូនទោល | តាមពេលជាក់ស្តែង | ៤០០ ០០០ រៀល |
| | សម្រាលកូនភ្លោះពីរ | តាមពេលជាក់ស្តែង | ៦០០ ០០០ រៀល |
| | សម្រាលកូនភ្លោះបី | តាមពេលជាក់ស្តែង | ៨០០ ០០០ រៀល |
| ដំណាក់កាលទី៣ | ពិនិត្យក្រោយសម្រាលលើកទី១ (ពិនិត្យទាំងម្តាយ និងទាំងកូន) | ថ្ងៃទី៧ ក្រោយសម្រាល | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី២ ពិនិត្យទាំងម្តាយ និងទាំងកូន) | ថ្ងៃទី១៤ក្រោយសម្រាល | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៣ (ពិនិត្យទាំងម្តាយ និងទាំងកូន) | កូនមានអាយុ១ខែកន្លះ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៤ (ពិនិត្យសុខភាពកូន) | កូនមានអាយុ២ខែកន្លះ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៥ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៣ខែកន្លះ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៦ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៦ខែ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៧ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៩ខែ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៨ (ពិនិត្យសុខភាពកូន) | កូនមានអាយុ១២ខែ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី៩ (ពិនិត្យសុខភាពកូន) | កូនមានអាយុ១៨ខែ | ៨០ ០០០ រៀល |
| | ពិនិត្យក្រោយសម្រាលលើកទី១០ (ពិនិត្យសុខភាពកូន) | កូនមានអាយុ២៤ខែ | ៨០ ០០០ រៀល |

### ៥.៤. ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងសិទ្ធិផ្សេងទៀត

គ្រួសារដែលទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមក្នុងក្របខណ្ឌនេះ អាចទទួលបានការគាំទ្រផ្សេងៗ ដែលផ្តល់ដោយរាជរដ្ឋាភិបាល ទៅតាមលក្ខណវិនិច្ឆ័យនៃការគាំទ្រទាំងនោះ។ អត្ថប្រយោជន៍ និងការគាំទ្រទាំងនេះអាចរួមមាន អត្ថប្រយោជន៍ពីមូលនិធិសមធម៌សុខាភិបាល កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ការទទួលបានសេវាថែទាំសុខភាពចាំបាច់ (សុខភាពមាតា សុខភាពផ្លូវភេទ និងបន្តពូជ) សេវាសង្គមកិច្ច សេវាការពារកុមារ និងសេវាសម្រាប់ជនមានពិការភាពដែលផ្តល់ដោយ

រាជរដ្ឋាភិបាល។ អ្នកទទួលផលរបស់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ក៏អាចប្រើប្រាស់របបសន្តិសុខសង្គមក្រោមបេឡាជាតិសន្តិសុខសង្គម ផងដែរ។

## ៥.៥. លក្ខខណ្ឌនៃការចាកចេញ

ខាងក្រោមនេះ ជាលក្ខខណ្ឌចាកចេញទូទៅសម្រាប់គ្រួសារ ដែលទទួលបានអត្ថប្រយោជន៍ពីកញ្ចប់គ្រួសារ៖

**មរណភាពនៃអ្នកទទួលផល៖** នៅពេលជនចាស់ជរាដែលកំពុងទទួលបានប្រាក់ឧបត្ថម្ភ, កុមារកំពុងទទួលបានអាហារូបករណ៍ ឬជនមានពិការភាពកំពុងទទួលបានប្រាក់ឧបត្ថម្ភទទួលមរណភាព, ការបើកផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់ជុំបន្ទាប់ នឹងត្រូវផ្ដល់ជូនគ្រួសារ ហើយប្រាក់ឧបត្ថម្ភនោះនឹងត្រូវបានបញ្ឈប់ភ្លាមៗ។ សម្រាប់ម្ដាយដែលកំពុងទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ឬអាហារូបករណ៍ ឬប្រាក់ឧបត្ថម្ភជនមានពិការភាពសម្រាប់កុមារ, អ្នកទទួលផលពេញវ័យថ្មីមួយ នឹងត្រូវបានជ្រើសតាំងឱ្យទទួលប្រាក់ឧបត្ថម្ភ ក្នុងករណីម្ដាយទទួលមរណភាព ហើយកុមារនោះនៅមានសិទ្ធិទទួលបានអត្ថប្រយោជន៍។

**ការចាកចេញដោយស្ម័គ្រចិត្ត៖** គ្រួសារអាចសម្រេចចិត្តឈប់ចូលរួម ឬឈប់ទទួលអត្ថ-ប្រយោជន៍ ពីកម្មវិធី ដោយការចាកចេញដោយស្ម័គ្រចិត្ត ដែលត្រូវមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ-សង្កាត់។ ការបើកផ្ដល់អត្ថប្រយោជន៍ដល់គ្រួសារនោះ នឹងត្រូវបញ្ឈប់ភ្លាមៗ។

**ការក្លែងបន្លំ/ប្រតិជ្ញព័ត៌មានមិនពិត៖** គ្រួសារណាដែលផ្ដល់ព័ត៌មានក្លែងបន្លំ (ករណីមានភស្តុតាង) អាចត្រូវបានដកចេញពីកម្មវិធី ហើយការបើកផ្ដល់នឹងត្រូវបញ្ឈប់ភ្លាមៗ។

**ស្ថានភាពក្រីក្រ៖** បន្ទាប់ពីបញ្ចូលក្នុងកម្មវិធី, គ្រួសារនៅបន្តទទួលបានអត្ថប្រយោជន៍ ករណីកម្មវិធីកំពុងត្រូវបានអនុវត្ត ហើយពួកគេបានបំពេញតាមលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌកម្មវិធីគ្រប់គ្រាន់។ ករណីគ្រួសារលែងត្រូវបានចាត់ទុកជាគ្រួសារក្រីក្រ និងងាយរងគ្រោះ យោងតាមលក្ខណវិនិច្ឆ័យ (ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ) គ្រួសារនោះនឹងមិនទទួលបានអត្ថប្រយោជន៍បន្តទៀតឡើយ។

**អាយុ៖** កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ មានភ្ជាប់លក្ខខណ្ឌអាយុ។ ដូចនេះ នៅពេលដែលកុមារមានអាយុលើសពីអាយុកំណត់ កុមារនោះនឹងចាកចេញពីកម្មវិធីដោយស្វ័យប្រវត្តិ។

## ៦. ប្រព័ន្ធគាំទ្រការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ

ដើម្បីឱ្យការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពពេញលេញ, រាជរដ្ឋាភិបាលបន្តវិនិយោគលើការពង្រឹងប្រព័ន្ធសំខាន់ៗមួយចំនួនដូចខាងក្រោម៖

### ៦.១. អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ និងការបង្កើនបរិយាបន្ន

អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបរិយាបន្នមួយ តម្រូវឱ្យមានការពង្រីក ឬកែសម្រួលវិធីសាស្ត្រ និងយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ រាជរដ្ឋាភិបាល តាមរយៈក្រសួងផែនការ បានបន្តកិច្ចខិតខំកែលម្អយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាបន្តបន្ទាប់ ដែលរំពឹងថានឹងបង្កើនបរិយាបន្នចំពោះក្រុមជនងាយរងគ្រោះបន្ថែម ក្រៅពីអ្នកដែលរស់នៅក្នុងភាពក្រីក្រ ដើម្បីដាក់បញ្ចូលបន្ថែមអ្នកដែលហានិភ័យ ប្រឈមនឹងការធ្លាក់ចូលក្នុងភាពក្រីក្រ។

ការបន្តកែសម្រួលយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គប្បីពិចារណាលើសូចនាករពាក់ព័ន្ធនឹងលទ្ធផលចុងក្រោយដែលក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ព្យាយាមសម្រេចបាន។ ក្នុងកម្រិតអប្បបរមាជាមូលដ្ឋានមួយសូចនាករទាំងនោះ គួររួមបញ្ចូលលទ្ធភាពទទួលបានសេវាសុខភាព អាហារ ទឹកស្អាត និងអនាម័យ, ភាពធន់ផ្នែកសេដ្ឋកិច្ច, ប្រភេទការងារ (ការងារដែលងាយរងគ្រោះ ឬក្នុងវិស័យងាយរងគ្រោះ), កង្វះអាហារូបត្ថម្ភ, ភាពមិនអាចចល័តបានពាក់ព័ន្ធនឹងកត្តាអាយុ, បញ្ហាប្រឈមក្នុងការទទួលបាន (Accessibility) ពាក់ព័ន្ធនឹងពិការភាព, កិច្ចការពារពិសេស និងកង្វល់ពាក់ព័ន្ធនឹងយេនឌ័រ, និងសូចនាករបែបនេះផ្សេងទៀត ដែលងាយវាស់វែង និងបង្ហាញពីហានិភ័យរបស់គ្រួសារ និងបុគ្គល ក្នុងការសម្រេចបាននូវការអភិវឌ្ឍមូលធនមនុស្ស និងផលិតភាពក្នុងកម្រិតអតិបរមាមួយ។ ជាមួយគ្នានេះ សូចនាករផ្សេងទៀតពាក់ព័ន្ធនឹងការចូលរួមសកម្មភាពសង្គម និងតម្រូវការមូលធនរបស់ជនមានពិការភាព ឬអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ក៏អាចរួមបញ្ចូលបន្ថែម ផងដែរ។

### ៦.២. ពង្រឹងប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់

ប្រព័ន្ធបញ្ជូនបន្ត និងបណ្ដាញតភ្ជាប់ទៅកាន់សេវា និងកម្មវិធីផ្សេងៗ មានសារៈសំខាន់សម្រាប់ប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈទូលំទូលាយ។ ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងកសាងមូលដ្ឋានគ្រឹះ ដើម្បីធ្វើឱ្យមានភាពងាយស្រួលសម្រាប់ការបញ្ជូនបន្ត និងតភ្ជាប់ការឧបត្ថម្ភសាច់ប្រាក់ ទៅកាន់សេវា និងកម្មវិធីនានា រួមមានកម្មវិធីគាំពារសង្គមផ្សេងៗ កម្មវិធីទីផ្សារការងារសកម្ម (Active Labour Market Programmes) និងសេវាសង្គមកិច្ច ដែលរាប់បញ្ចូលទាំងសេវាសង្គមកិច្ចសម្រាប់ជនមានពិការភាព ជនចាស់ជរា និងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ហើយក៏អាចពង្រីកបន្ថែមដល់ការបញ្ជូនបន្ត និងតភ្ជាប់ទៅកាន់ក្រុមស្ត្រី និងកិច្ចពង្រឹងសិទ្ធិអំណាចស្ត្រី ផងដែរ។

ក្នុងកម្រិតអប្បបរមា, ប្រព័ន្ធបញ្ជូនបន្ត និងបណ្ដាញតភ្ជាប់អាចធ្វើឱ្យបុគ្គល និងគ្រួសារដែលមានលក្ខខណ្ឌគ្រប់គ្រាន់ មានភាពងាយស្រួលក្នុងការទទួលបានអត្ថប្រយោជន៍ ឬត្រូវបានបញ្ជូនបន្តទៅទទួលផលពីកម្មវិធីផ្តល់អាហារតាមសាលារៀន, កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ

និងមូលនិធិសមធម៌សុខាភិបាល។ បន្ទាប់មក រាជរដ្ឋាភិបាលអាចពង្រីកបន្ថែមទៅកាន់សេវាសង្គមកិច្ចផ្សេងទៀត ដែលមានស្រាប់។

នៅដំណាក់កាលបន្ត, រាជរដ្ឋាភិបាលនឹងពង្រីកប្រព័ន្ធគាំពារសង្គមឱ្យកាន់តែទូលំទូលាយ និងមានលក្ខណៈសមាហរណៈ។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ, ការវិនិយោគលើសមត្ថភាព និងប្រព័ន្ធនានា មានភាពចាំបាច់ ដែលជំហានដំបូងត្រូវពង្រីក **សមត្ថភាពរបស់ប្រព័ន្ធបញ្ជូនបន្ត និងចំណុចចាប់ផ្តើម (Entry Points) ចូលទៅកាន់កម្មវិធី** ក្នុងគោលបំណងពង្រីកបណ្តាញតភ្ជាប់រវាងកម្មវិធី និងបង្កើនផលជះពហុវិស័យរបស់កម្មវិធី។ ការបង្កើតឱ្យមានចំណុចចាប់ផ្តើមច្រើនចូលទៅកាន់កម្មវិធី នឹងធានាបាននូវមុខងារ ដែលមានលក្ខណៈប្រទាក់ក្រឡា និងទូលំទូលាយ តាមរយៈការចូលរួមពីតួអង្គនៅថ្នាក់មូលដ្ឋាន និងតម្រូវឱ្យមានការរៀបចំជាស្តង់ដារ និងការធានាគុណភាពរបស់អ្នកផ្តល់សេវា។

**រូបភាពទី៣ ៖ ក្របខណ្ឌសមាហរណកម្មប្រព័ន្ធជំនួយសង្គម**




ការបង្កើតកម្លាំងសេវាសង្គមដ៏រឹងមាំ (វិជ្ជាជីវៈ និងពាក់កណ្តាលវិជ្ជាជីវៈ) មានសារៈសំខាន់សម្រាប់ដំណើរការប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់នេះ។ ប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់ដ៏រឹងមាំរវាងប្រព័ន្ធជំនួយសង្គម សេវាសង្គមកិច្ច និងរបបសន្តិសុខសង្គម អាចជួយពង្រឹងការសម្រេចបានលទ្ធផលចុងក្រោយនៃជំនួយសង្គម។ យន្តការគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារតែមួយមិនគ្រប់គ្រាន់សម្រាប់ការបញ្ជូនបន្ត, ការតាមដានត្រួតពិនិត្យសេវា, និងធានាគុណភាពសេវា ដែលមិនអាចក្លាយជាប្រព័ន្ធបញ្ជូនបន្តដ៏ល្អមួយសម្រាប់ប្រព័ន្ធគាំពារសង្គមបានឡើយ។ ការវិនិយោគលើការបណ្តុះបណ្តាលកម្លាំងសេវាសង្គម និងការដាក់ពង្រាយកម្លាំងសេវាសង្គម មានសារៈសំខាន់ណាស់

ក្នុងការគាំទ្រដល់កិច្ចគាំពារសង្គម កិច្ចការពារកុមារ និងក្រុមងាយរងគ្រោះផ្សេងៗ ដូចជាជនចាស់ជរា ជនមានពិការភាព អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងក្រុមងាយរងគ្រោះដទៃទៀត។ ការបង្កើត កម្លាំងសេវាសង្គមនឹងអនុញ្ញាតឱ្យមានចំណុចចាប់ផ្តើមជាច្រើន សម្រាប់ការកំណត់អត្តសញ្ញាណ ជនងាយរងគ្រោះ ហើយអាចបង្កើតជាក្រុមការងារគ្រប់គ្រងសេវាសង្គម និងគ្រប់គ្រងករណី ដែល មានសមត្ថភាពក្នុងការអភិវឌ្ឍផែនការបញ្ជូនបន្ត និងធ្វើសកម្មភាពគ្រប់គ្រងករណី។ កម្លាំងសេវាសង្គម ត្រូវពង្រឹងនៅថ្នាក់ឃុំសង្កាត់ ដោយមានការគាំទ្រពីក្រុមប្រឹក្សាឃុំ-សង្កាត់, គណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារ, មូលដ្ឋានសុខាភិបាលសាធារណៈ ឬគណៈកម្មាការគ្រប់គ្រងមណ្ឌលសុខភាព និងសាលារៀន, ឬគណៈកម្មាធិការសាលារៀន ហើយយន្តការស្ថាប័នដូចគ្នានេះ ចាំបាច់ត្រូវបង្កើត នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីគាំទ្រថ្នាក់ឃុំសង្កាត់។

### ៦.៣. ការបង្កើនភាពបត់បែន ភាពធន់ និងការឆ្លើយតបនឹងគ្រោះអាសន្ន

ការបង្កើនភាពបត់បែន និងភាពធន់នៃប្រព័ន្ធគាំពារសង្គម មានសារៈសំខាន់ខ្លាំង ក្នុងការ ឆ្លើយតបនឹងគ្រោះអាសន្ន។ ដើម្បីសម្រេចគោលដៅនេះ, ការធ្វើសមាហរណកម្មប្រព័ន្ធសំខាន់ៗមួយចំនួន ត្រូវសម្រេចឱ្យបាន ដែលក្នុងនោះរួមមានសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់ប្រព័ន្ធ គាំពារសង្គម ជាមួយនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងមូលដ្ឋានទិន្នន័យសំខាន់ៗដទៃទៀត ដើម្បី បង្កើតជាមូលដ្ឋានទិន្នន័យចុះបញ្ជីសង្គម (Social Registry)។ មូលដ្ឋានទិន្នន័យប្រព័ន្ធចុះបញ្ជីសង្គម បំពេញបន្ថែមដោយអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងងាយរងគ្រោះ និងយន្តការតាមការស្នើសុំ (On-Demand) បូករួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធបើកផ្តល់ឌីជីថល នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាល មានលទ្ធភាពពង្រីកវិសាលភាពគ្របដណ្តប់កម្មវិធីតាមខ្សែផ្តេក និងខ្សែបញ្ឈរ ក្នុងអំឡុងពេលមាន គ្រោះអាសន្ន។

ខណៈដែលការធ្វើសមាហរណកម្មប្រព័ន្ធឌីជីថលទាំងអស់កំពុងដំណើរការនៅកម្ពុជា សមត្ថភាព របស់ប្រព័ន្ធគាំពារសង្គមក្នុងការកំណត់អត្តសញ្ញាណជនងាយរងគ្រោះ និងឆ្លើយតបនឹងគ្រោះអាសន្ន បានឆាប់រហ័ស នឹងត្រូវបានបង្កើនដោយស្វ័យប្រវត្តិ។

## ៧. យន្តការស្ថាប័ន

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នឹងត្រូវអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តកិច្ចគាំពារសង្គម ក្នុងប្រទេសកម្ពុជា។ ក្រុមប្រឹក្សាជាតិគាំពារសង្គម មានតួនាទីក្នុងការបន្សុីកម្មវិធី ដើម្បីធ្វើឱ្យប្រព័ន្ធគាំពារសង្គមទាំងមូល កាន់តែមានភាពទូលំទូលាយ និងមូលនិធិជាតិជំនួយសង្គម ដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលហិរញ្ញវត្ថុ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត មានតួនាទីជានាពង្រឹងការផ្តល់សេវា ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្រូវការរក្សាគុណភាពសេវា និងគាំទ្រដល់ការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

### ៧.១. ស្ថាប័នថ្នាក់ជាតិ

#### ៧.១.១.ក្រុមប្រឹក្សាជាតិគាំពារសង្គម និងអគ្គលេខាធិការដ្ឋាន

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទីសម្របសម្រួលប្រព័ន្ធគាំពារសង្គមទាំងមូល នៅកម្ពុជា។ ក្រុមប្រឹក្សាជាតិគាំពារសង្គមផ្តល់ការណែនាំ និងតម្រង់ទិសគោលនយោបាយដល់មូលនិធិជាតិជំនួយសង្គម។

**ក្រុមប្រឹក្សាជាតិគាំពារសង្គម** មានតួនាទី៖

- ជានាឱ្យមានការបន្សុីកម្មវិធី និងគោលនយោបាយគាំពារសង្គម
- ផ្តល់ទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម
- តាមដាន វាយតម្លៃ និងពិនិត្យមើលជារួមលើការអនុវត្តប្រព័ន្ធគាំពារសង្គមទាំងមូល។

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម** មានតួនាទី៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តកម្មវិធីប្រព្រឹត្តទៅដោយរលូន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធី ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម
- សម្របសម្រួលការពិភាក្សាលើការស្នើសុំថវិកា
- តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី
- អនុវត្តការងារផ្សេងៗ តាមការណែនាំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

#### ៧.១.២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ អាណាព្យាបាល បច្ចេកទេស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអាណាព្យាបាលដឹកនាំផ្នែកបច្ចេកទេសសម្រាប់កម្មវិធីគាំពារសង្គម ដែលអនុវត្តដោយមូលនិធិជាតិជំនួយសង្គម។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកផ្នែកបច្ចេកទេសរបស់មូលនិធិជាតិជំនួយសង្គម លើផែនការគោលនយោបាយ, ការតាមដាន និងវាយតម្លៃ, និងការតម្រង់ទិសរចនាសម្ព័ន្ធស្ថាប័ន។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានតួនាទី៖

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់មូលនិធិជាតិជំនួយសង្គមអនុវត្ត
- ពិនិត្យ និងសម្រេចផែនការអភិវឌ្ឍន៍របស់មូលនិធិជាតិជំនួយសង្គម
- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងផែនការថវិកាប្រចាំឆ្នាំរបស់មូលនិធិជាតិជំនួយសង្គម
- ពិនិត្យ និងសម្រេចលើការស្នើសុំចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់មូលនិធិជាតិជំនួយសង្គម
- ណែនាំវិធានការដោះស្រាយពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់មូលនិធិជាតិជំនួយសង្គម
- ពិនិត្យ និងសម្រេចលើរចនាសម្ព័ន្ធរបស់មូលនិធិជាតិជំនួយសង្គម
- ពិនិត្យ និងផ្តល់យោបល់លើផែនការអភិវឌ្ឍន៍, ផែនការថវិកា, របាយការណ៍ហិរញ្ញវត្ថុ, និងឯកសារផ្សេងទៀតរបស់មូលនិធិជាតិជំនួយសង្គម ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច។

### ៧.១.៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ អាណាព្យាបាលហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលហិរញ្ញវត្ថុរបស់មូលនិធិជាតិជំនួយសង្គម មានតួនាទីធ្វើអធិការកិច្ច, សវនកម្ម, តាមដាន និងវាយតម្លៃលើប្រតិបត្តិការនានារបស់មូលនិធិជាតិជំនួយសង្គម។

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានតួនាទី៖

- ពិនិត្យ ផ្តល់យោបល់ និងអនុម័តផែនការអភិវឌ្ឍន៍ និងការស្នើសុំថវិការបស់មូលនិធិជាតិជំនួយសង្គម
- វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពិនិត្យរបាយការណ៍អនុវត្តថវិកា និងឯកសារផ្សេងៗ ផ្អែកលើសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងសម្រេច ឬអនុម័តឯកសារដទៃទៀត តាមការស្នើសុំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមូលនិធិជាតិជំនួយសង្គម ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តនូវវិធាន និងនីតិវិធីចំណូល-ចំណាយ, បទដ្ឋានចំណូល-ចំណាយ និងបទដ្ឋានគតិយុត្តដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់មូលនិធិជាតិជំនួយសង្គម។

### ៧.១.៤. ក្រសួងផែនការ

ដោយក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ប្រើប្រាស់យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រសម្រាប់ការកំណត់អត្តសញ្ញាណអ្នកទទួលផល ក្រសួងផែនការ ត្រូវគាំទ្រមូលនិធិជាតិជំនួយសង្គមក្នុងការធ្វើសមាហរណកម្មទិន្នន័យ ការគ្រប់គ្រងទិន្នន័យ និងសមាហរណកម្មប្រព័ន្ធទិន្នន័យទាំងអស់។

**ក្រសួងផែនការ** មានតួនាទី៖

- ផ្តល់លទ្ធភាពទទួលបានទិន្នន័យគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលត្រូវធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី តាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (API)
- បន្តកែសម្រួលយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីរួមបញ្ចូលជនងាយរងគ្រោះបន្ថែម
- ផ្តល់ការគាំទ្របច្ចេកទេសសម្រាប់កត់ត្រាទិន្នន័យគ្រួសារក្រីក្រនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- សហការជាមួយមូលនិធិជាតិជំនួយសង្គម ក្នុងការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី
- ឆ្លើយតបឱ្យបានទាន់ពេលទៅនឹងបញ្ហាប្រឈមនៃការអនុវត្ត។

### ៧.១.៥. ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ ពិនិត្យមើលជារួមលើរដ្ឋបាលសាធារណៈ និងពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក្រសួងមហាផ្ទៃ** មានតួនាទី៖

- សហការជាមួយមូលនិធិជាតិជំនួយសង្គម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ថ្នាក់ឃុំ-សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- ពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធី
- សហការជាមួយមូលនិធិជាតិជំនួយសង្គម ក្នុងការតាមដាន និងវាយតម្លៃការអនុវត្តកញ្ចប់គ្រួសារ។

### ៧.១.៦. ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល សម្របសម្រួលការបន្សុីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារជាមួយមូលនិធិសមធម៌សុខាភិបាល និងសមាសភាគផ្នែកសុខាភិបាលដែលមានក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ក្រសួងសុខាភិបាលមានភារកិច្ចពង្រឹងយន្តការបញ្ជាក់ការអនុវត្តលក្ខខណ្ឌ បញ្ជូនបន្ត តាមដាន និងផ្តល់សុពលភាព ដែលមានសារៈសំខាន់សម្រាប់កម្មវិធី។

**ក្រសួងសុខាភិបាល** មានតួនាទី៖

- ធានាការផ្តល់សេវាថែទាំសុខភាព ដែលពាក់ព័ន្ធនឹងកម្មវិធី ប្រកបដោយគុណភាព
- គាំទ្រការកំណត់អត្តសញ្ញាណ និងផ្ទៀង ឬបញ្ជាក់ជនមានពិការភាព អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីជួយសម្រួលដល់ការចុះឈ្មោះចូលកម្មវិធី
- គាំទ្រការអនុវត្តកម្មវិធី។

### ៧.១.៧. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីគាំទ្រក្នុងការផ្តល់អាហារូបករណ៍ផ្អែកលើសមធម៌ និងភាពក្រីក្រ ដែលជាផ្នែកមួយនៃក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

**ក្រសួងអប់រំ យុវជន និងកីឡា** មានតួនាទី៖

- គាំទ្រដំណើរផ្លាស់ប្តូរមុខងារកម្មវិធីអាហារូបករណ៍ផ្អែកលើសមធម៌ និងភាពក្រីក្រទៅក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលអនុវត្តដោយមូលនិធិជាតិជំនួយសង្គម
- ធានាការផ្តត់ផ្គង់សេវាអប់រំប្រកបដោយគុណភាព
- គាំទ្រការអនុវត្តកម្មវិធី។

### ៧.១.៨. មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)

មូលនិធិជាតិជំនួយសង្គម មានភារកិច្ចអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលមានក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលហិរញ្ញវត្ថុ និងស្ថិតក្រោមការណែនាំ និងតម្រង់ទិសគោលនយោបាយពីក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មូលនិធិជាតិជំនួយសង្គម** មានតួនាទី៖

- ធានាថាកម្មវិធីជំនួយសង្គមទាំងអស់ក្រោមកញ្ចប់គ្រួសារមានដំណើរការរលូន និងមានប្រសិទ្ធភាព
- ដំណើរការអនុវត្តកម្មវិធីប្រចាំថ្ងៃ រួមទាំងការកំណត់ និងការគ្រប់គ្រងបញ្ជរបើកផ្តល់ និងគ្រឹះស្ថានបើកផ្តល់ (Payment Providers)
- ធានាការរៀបចំថវិកាសម្រាប់អនុវត្តកម្មវិធី និងរៀបចំផែនការត្រៀមបម្រុងដើម្បីដោះស្រាយបញ្ហាប្រឈមដែលអាចកើតឡើង និងធានានិរន្តរភាពរបស់កម្មវិធី
- តាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាប្រចាំ, កំណត់បញ្ហាប្រឈម, និងដោះស្រាយតាមការចាំបាច់ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទប្បញ្ញត្តិ និងតួនាទីដែលបានកំណត់
- បង្កើត និងពិនិត្យបទប្បញ្ញត្តិ ដើម្បីកែលម្អការអនុវត្តកម្មវិធី តាមការចាំបាច់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីពង្រឹងសមត្ថភាពអ្នកអនុវត្តកម្មវិធី
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីអនុវត្តកម្មវិធី
- ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី និងគាំទ្រការដោះស្រាយបញ្ហាប្រឈមនានា
- រៀបចំរបាយការណ៍ជាទៀងទាត់ ដើម្បីដាក់ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្តល់របាយការណ៍ ទិន្នន័យ ព័ត៌មាន និងការបំភ្លឺព័ត៌មាន តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ៧.២. រដ្ឋបាលថ្នាក់រាជធានី-ខេត្ត

មន្ទីរជំនាញពាក់ព័ន្ធនៅថ្នាក់រាជធានី-ខេត្ត មានតួនាទីសម្របសម្រួលការអនុវត្តកម្មវិធីជាតិជំនួយសង្គម ក្នុងការដឹកនាំ និងណែនាំដល់អង្គភាពថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ តាមការចាំបាច់។

### ៧.២.១. រដ្ឋបាលរាជធានី-ខេត្ត

**រដ្ឋបាលរាជធានី-ខេត្ត** មានតួនាទី៖

- សម្របសម្រួលជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ការិយាល័យជំនាញពាក់ព័ន្ធនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់ឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- គាំទ្រការរៀបចំ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- ដឹកនាំកិច្ចប្រជុំថ្នាក់រាជធានី ខេត្ត ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

### ៧.២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មានតួនាទី៖

- គាំទ្រ និងតាមដានការអនុវត្តកម្មវិធី តាមការតម្រូវរបស់មូលនិធិជាតិជំនួយសង្គម
- សម្របសម្រួលជាមួយមន្ទីរពាក់ព័ន្ធក្នុងខេត្ត ដឹកនាំ និងតាមដានការអនុវត្តកម្មវិធី។

### ៧.២.៣. មន្ទីរសុខាភិបាលរាជធានី ខេត្ត

មន្ទីរសុខាភិបាលរាជធានី ខេត្ត គាំទ្រ និងសម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការប្រមូលទិន្នន័យ និងធានាគុណភាពនៃសេវាពាក់ព័ន្ធនឹងអ្នកទទួលផលរបស់កម្មវិធី ដោយមានតួនាទី៖

- ធានាការផ្តល់សេវាថែទាំសុខភាពពាក់ព័ន្ធនឹងកម្មវិធី ប្រកបដោយគុណភាព
- គាំទ្រការអនុវត្តសេវាសំខាន់ៗពាក់ព័ន្ធនឹងកម្មវិធី ប្រកបដោយគុណភាពតាមការចាំបាច់
- ធានាផ្តល់មុខងារពាក់ព័ន្ធនឹងកម្មវិធី តាមការតម្រូវរបស់មូលនិធិជាតិជំនួយសង្គម។

### ៧.២.៤. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ធ្វើការសម្របសម្រួលសកម្មភាពពាក់ព័ន្ធនឹងកម្មវិធីអាហារូបករណ៍ ដោយមានតួនាទី៖

- គាំទ្រការផ្តល់សេវាសំខាន់ៗពាក់ព័ន្ធនឹងកម្មវិធី ប្រកបដោយគុណភាព តាមការចាំបាច់
- ធានាផ្តល់មុខងារពាក់ព័ន្ធនឹងកម្មវិធី តាមការតម្រូវរបស់មូលនិធិជាតិជំនួយសង្គម។

### ៧.២.៥. គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (គ.ក.ស.ក.) រាជធានី ខេត្ត

គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ រាជធានី ខេត្ត (**គ.ក.ស.ក.**) មានតួនាទីធ្វើការជាមួយ **គ.ក.ស.ក** នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ ដើម្បីធានាថាពួកគេបានត្រៀមខ្លួនក្នុងការផ្តល់ការគាំទ្រចាំបាច់សម្រាប់ការអនុវត្តកម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ រាជធានី ខេត្ត មានតួនាទី៖

- គាំទ្រការអនុវត្តសេវាសំខាន់ៗពាក់ព័ន្ធនឹងកម្មវិធី ប្រកបដោយគុណភាព តាមការចាំបាច់

- សម្របសម្រួល និងជំរុញកិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរនៃក្រសួងពាក់ព័ន្ធ តាមការតម្រូវរបស់មូលនិធិជាតិជំនួយសង្គម ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

## ៧.៣. ថ្នាក់ក្រុង ស្រុក ខណ្ឌ

### ៧.៣.១. គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ

- គាំទ្រការអនុវត្តកញ្ចប់គ្រួសារ។

### ៧.៣.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

- គាំទ្រការសម្របសម្រួលរវាងរដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ រាជធានី ខេត្ត និង មន្ទីរជំនាញ រាជធានី ខេត្តនានា សម្រាប់ការអនុវត្តកម្មវិធី តាមការតម្រូវរបស់មូលនិធិជាតិជំនួយសង្គម
- គាំទ្រ និងដឹកនាំការបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាព ការតាមដាន និងវាយតម្លៃកម្មវិធី ស្របតាមតួនាទីដែលបានកំណត់ក្នុងយន្តការតាមដាន និងវាយតម្លៃ។

## ៧.៤. ថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិ

### ៧.៤.១. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំដោយមេឃុំ ចៅសង្កាត់ និងមានជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ ជាជំនួយការ មានតួនាទីអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចសម្របសម្រួលការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារដែលក្នុងនោះរួមមានការលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹង, ការចុះឈ្មោះ, ការកត់ត្រា និងការគ្រប់គ្រងបណ្ដឹងតវ៉ា, ការសម្របសម្រួលជាមួយដៃគូអនុវត្តផ្សេងទៀត និងការរាយការណ៍ជូនថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត។

### ៧.៤.២. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ មានតួនាទីសម្របសម្រួល និងផ្ដល់សេវាសង្គមកិច្ចនៅថ្នាក់ឃុំ សង្កាត់ និងភូមិ។ គណៈកម្មាធិការនេះគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី ដោយគាំទ្រលើការវាយតម្លៃហានិភ័យ និងបញ្ហាប្រឈម, លើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធី, ចុះឈ្មោះ, កត់ត្រា, គ្រប់គ្រងបណ្ដឹងតវ៉ា, សម្របសម្រួលជាមួយដៃគូអនុវត្តផ្សេងទៀត និងធ្វើការបញ្ជូនកម្មវិធីជាមួយសេវាសង្គមកិច្ចដែលមាននៅតាមសហគមន៍។

### ៧.៤.៣. សាលារៀន

សាលារៀន និងគ្រឹះស្ថានអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងផ្ដល់សេវា ដែលពាក់ព័ន្ធនឹងកម្មវិធី។ សាលារៀន និងគ្រឹះស្ថានអប់រំទទួលបន្ទុកតាមដានការអនុវត្តលក្ខខណ្ឌរបស់សិស្ស, ផ្ដល់ទិន្នន័យតាមដាន និងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ ពាក់ព័ន្ធនឹងសកម្មភាព និងសមាសភាគអប់រំក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

### ៧.៤.៤. មណ្ឌលសុខភាព

មណ្ឌលសុខភាព មានតួនាទីផ្តល់សេវាថែទាំសុខភាពដែលមានគុណភាពដល់អ្នកទទួលផលរបស់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ មណ្ឌលសុខភាពទទួលបន្ទុកផ្តល់ឯកសារចាំបាច់ សម្រាប់ការផ្ទៀងលក្ខខណ្ឌសិទ្ធិទទួលផល និងសម្រាប់ការចុះឈ្មោះស្ត្រីមានផ្ទៃពោះ និងជនមានពិការភាពទៅក្នុងកម្មវិធី និងផ្តល់ទិន្នន័យតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ពាក់ព័ន្ធនឹងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

មណ្ឌលសុខភាពត្រូវបញ្ជូន ឬចែករំលែកព័ត៌មានឱ្យបុគ្គលដែលបានធ្វើតេស្តរហ័ស និងមានលទ្ធផលវិជ្ជមាន ដើម្បីបន្តធ្វើតេស្តបញ្ជាក់នៅតាមគ្លីនិកផ្តល់សេវាពិនិត្យព្យាបាលអ្នកជំងឺអេដស៍ ហើយក្នុងករណីលទ្ធផលបញ្ជាក់ថាវិជ្ជមាន គ្លីនិកទាំងនោះ ត្រូវកំណត់អត្តសញ្ញាណពួកគាត់ ស្របតាមនីតិវិធីជាធរមាន។

### ៧.៤.៥. ក្រុមតំណាងភូមិ និងក្រុមគាំទ្រសុខភាពភូមិ

ក្រុមតំណាងភូមិ ក្រុមគាំទ្រសុខភាពភូមិ រួមជាមួយនឹងមេភូមិ មានតួនាទីគាំទ្រការកំណត់អត្តសញ្ញាណ និងការបញ្ជូនបន្តនូវបុគ្គល និងគ្រួសារដែលងាយរងគ្រោះទៅកាន់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ផ្តល់ការគាំទ្រដល់គ្រួសារក្នុងការចុះឈ្មោះចូលកម្មវិធី, ដឹកនាំយុទ្ធនាការផ្សព្វផ្សាយ, លើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធី, ផ្តល់ការគាំទ្រក្នុងការទទួលបានអត្ថប្រយោជន៍, កត់ត្រា, និងគ្រប់គ្រងបណ្តឹងតវ៉ា។

### ៧.៤.៦. ភាពជាដៃគូ

ភាពជាដៃគូជាមួយគ្រឹះស្ថានបើកផ្តល់មានសារៈសំខាន់ សម្រាប់ភាពជោគជ័យរបស់កម្មវិធី។ ភាពជាដៃគូជាមួយគ្រឹះស្ថានបើកផ្តល់ច្រើននឹងធានាថាការផ្ទេរប្រាក់ឧបត្ថម្ភអាចត្រូវបានផ្តល់ដោយសេវាដែលមានថ្លៃទាប និងមានលក្ខណៈសមស្របបំផុតសម្រាប់អ្នកទទួលផល។ ការបើកផ្តល់សាច់ប្រាក់ដល់អ្នកទទួលផលប្រព្រឹត្តទៅតាមរយៈគ្រឹះស្ថានបើកផ្តល់នានា ដែលមានភារកិច្ច ដូចខាងក្រោម៖

**គ្រឹះស្ថានបើកប្រាក់**

ការឧបត្ថម្ភសាច់ប្រាក់ដោយផ្ទាល់ មានដំណើរការស្របតាមបទដ្ឋាន និងស្តង់ដារជាតិពីគ្រឹះស្ថានបើកផ្តល់ទៅអ្នកទទួលផល។ គ្រឹះស្ថានបើកផ្តល់ មានតួនាទី៖

- គាំទ្រការលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងពីការបើកផ្តល់ និងសេវាបើកផ្តល់
- លើកកម្ពស់អន្តរភាពផ្នែកហិរញ្ញវត្ថុ លើសេវាកម្មរបស់ខ្លួន
- ធ្វើសមាហរណកម្មសេវាបើកផ្តល់ជាមួយប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី
- ផ្តល់គណនី ផ្ទៀងការបើកផ្តល់ និងផ្តល់ការគាំទ្រចាំបាច់នានាដល់អ្នកទទួលផល។

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ គួរមានគ្រឹះស្ថានបើកផ្តល់ច្រើន សម្រាប់បើកផ្តល់ ដើម្បីធានាថាអ្នកទទួលផលនៅតំបន់ជនបទ និងទីប្រជុំជនអាចទទួលបាន និងប្រើប្រាស់សេវាបានយ៉ាងងាយស្រួល មានភាពបត់បែន មានជម្រើសកាន់តែច្រើន និងអាចកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាលក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភ។

## ៨. សកម្មភាពអន្តរកាល និងការត្រៀមខ្លួន

### ៨.១. ការអភិវឌ្ឍប្រព័ន្ធ និងសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានសម្រាប់ការអនុវត្តមុខងារចម្បងៗជាច្រើន។ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ជាប្រព័ន្ធមួយដែលមានលក្ខណៈសមាហរណ៍ និងដំណើរការការងារដោយស្វ័យប្រវត្តិសម្រាប់កម្មវិធីជំនួយសង្គមទាំងអស់។ ប្រព័ន្ធនេះត្រូវបានរំពឹងថា អាចបំពេញមុខងារសំខាន់ៗមួយចំនួន ដូចជាការកំណត់ក្រុមគោលដៅ, ការចុះឈ្មោះ, ការអនុវត្តលក្ខខណ្ឌ ការតាមដាន, និងការបើកផ្តល់ ក៏ដូចជាការដោះស្រាយបណ្តឹងតវ៉ា។

ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន, ការបង្កើតម៉ូឌុលបន្ថែមស្ថិតក្រោមការទទួលខុសត្រូវរបស់មូលនិធិជាតិជំនួយសង្គម។ នៅដំណាក់កាលអភិវឌ្ឍន៍នេះ, សកម្មភាពសំខាន់ៗដែលនឹងត្រូវបានអនុវត្តរួមមាន៖

- បង្កើតក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានជាមួយនឹងអ្នកជំនាញអភិវឌ្ឍន៍កម្មវិធី
- រៀបចំឱ្យមានសមត្ថភាពផ្ទៃក្នុង ដែលគ្រប់គ្រាន់ក្នុងការផ្ទុក ការគ្រប់គ្រង ការតាមដាន និងការធ្វើបច្ចុប្បន្នភាពថ្នាល និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានវិទ្យា
- សហការជាមួយក្រសួងផែនការ ដើម្បីធានាឱ្យការធ្វើសមាហរណកម្មប្រព្រឹត្តទៅដោយរលូនរវាងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រព័ន្ធចុះបញ្ជីសង្គមដែលនឹងត្រូវបានអភិវឌ្ឍនាពេលអនាគត ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ធានាឱ្យមានការតភ្ជាប់ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានផ្សេងៗរបស់ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធតាមដាន និងវាយតម្លៃ នៅពេលដែលប្រព័ន្ធទាំងនេះមានការវិវឌ្ឍ
- ធានាឱ្យមានការតភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យផ្សេងៗ និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពាក់ព័ន្ធផ្សេងទៀត សម្រាប់ការអនុវត្តកម្មវិធី
- ធ្វើការរួមគ្នាជាមួយគ្រឹះស្ថានបើកផ្តល់ ដើម្បីធានាថាការធ្វើសមាហរណកម្មប្រព័ន្ធបើកផ្តល់ជាមួយប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី មានដំណើរការទៅដោយរលូន
- រៀបចំឱ្យមានក្រុមការងារ ដើម្បីអភិវឌ្ឍសំណួរ ចម្លើយទូទៅ និងយន្តការដោះស្រាយបណ្តឹងតវ៉ា នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ធានារក្សាបាននូវឯកជនភាព និងសុវត្ថិភាពទិន្នន័យ
- ធ្វើតេស្តសាកល្បងការធ្វើសមាហរណកម្មទិន្នន័យ ២ ឬ ៣លើក ដើម្បីធានាថាទិន្នន័យត្រូវបានផ្ទេរ ឬដាក់បញ្ចូលគ្នាបានយ៉ាងរលូន និងដើម្បីកំណត់ និងដោះស្រាយបញ្ហាដែលបានរកឃើញ។

ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន រួមបញ្ចូលម៉ូឌុលមួយចំនួន ដូចខាងក្រោម៖

- ការចុះឈ្មោះចូលកម្មវិធី - ការបញ្ចូលទិន្នន័យនៅថ្នាក់ឃុំ សង្កាត់

- ការតាមដានការអនុវត្តលក្ខខណ្ឌ- ការបញ្ចូលទិន្នន័យនៅមូលដ្ឋានសុខាភិបាលសាធារណៈ និង សាលារៀន
- ការស្នើសុំបើកផ្តល់ និងការអនុម័ត - ការបញ្ចូលទិន្នន័យនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងសាលារៀន ការតាមដានទិន្នន័យ និងការអនុម័តនៅកម្រិតរាជធានី ខេត្ត
- ការបញ្ជាក់ការបើកផ្តល់ - ការធ្វើសមាហរណកម្មជាមួយប្រព័ន្ធរបស់គ្រឹះស្ថានបើកផ្តល់ និងការបញ្ចូលទិន្នន័យ ដោយគ្រឹះស្ថាននោះ
- ការដោះស្រាយបណ្តឹងតវ៉ា - ការបញ្ចូលទិន្នន័យនៅឃុំ សង្កាត់ ការឆ្លើយតប និងការគ្រប់គ្រងបណ្តឹងតវ៉ាដោយឃុំ សង្កាត់ មូលដ្ឋានសុខាភិបាលសាធារណៈ សាលារៀន និងមូលនិធិជាតិជំនួយសង្គម ដោយផ្អែកលើកម្រិតទម្ងន់នៃបណ្តឹងតវ៉ា
- ម៉ូឌុលបន្ថែម ដែលគាំទ្រការពង្រីកការគ្របដណ្តប់ និងវិសាលភាពនៃកម្មវិធី និងការតភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យគាំពារសង្គម។

ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាននឹងត្រូវអភិវឌ្ឍឡើង ដោយធានាបាននូវឯកជនភាពទិន្នន័យ និងការរឹតត្បិតសមត្ថភាពមើលទិន្នន័យរបស់បុគ្គលិក ដែលមិនទទួលខុសត្រូវចំពោះការងារជាក់លាក់ណាមួយដោយ៖

- ផ្តល់លទ្ធភាពចូលប្រើប្រាស់មុខងារពាក់ព័ន្ធក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានផ្អែកលើតួនាទី និងការទទួលខុសត្រូវនៅកម្រិតនីមួយៗ សម្រាប់អង្គភាព ឬស្ថាប័នសាធារណៈ
- ធានាថាទិន្នន័យអាចផ្លាស់ទីពីឃុំ សង្កាត់មួយ ទៅឃុំ សង្កាត់មួយទៀត នៅពេលផ្លាស់ប្តូរទីលំនៅ
- ធានាឱ្យមានការគ្រប់គ្រងហានិភ័យគ្រប់គ្រាន់ ដើម្បីជៀសវាងនូវការបញ្ចូលទិន្នន័យខុស, ទិន្នន័យត្រួតគ្នា, ទិន្នន័យរំលង, ឬ ទិន្នន័យមិនគ្រប់។

## ៨.២. ការរៀបចំឯកសារបណ្តុះបណ្តាល

ឯកសារបណ្តុះបណ្តាលលម្អិត ចាំបាច់ត្រូវរៀបចំឡើងដើម្បីធានាឱ្យការអនុវត្តកម្មវិធីមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ដើម្បីរៀបចំឯកសារបណ្តុះបណ្តាល មូលនិធិជាតិជំនួយសង្គមត្រូវ៖

- ធានាថាក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន រៀបចំសៀវភៅណែនាំ និងឯកសារបណ្តុះបណ្តាលលម្អិត សម្រាប់មុខងារនីមួយៗរបស់កម្មវិធី តាមកម្រិតស្ថាប័ននីមួយៗ
- ធានាថាសៀវភៅណែនាំប្រតិបត្តិគោល និងឯកសារបណ្តុះបណ្តាល ត្រូវបានផ្តល់ជូនស្ថាប័ននៅគ្រប់កម្រិត។

## ៨.៣. ការបណ្តុះបណ្តាលមន្ត្រីអនុវត្តកម្មវិធី

នៅពេលកម្មវិធីត្រូវបានដាក់ឱ្យដំណើរការ និងពង្រីក, មូលនិធិជាតិជំនួយសង្គម និងក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តកម្មវិធី ត្រូវផ្តល់ការបណ្តុះបណ្តាលដល់អ្នកអនុវត្តកម្មវិធីទាំងអស់នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលរួមមានសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- ក្រសួងមហាផ្ទៃចេញសេចក្តីណែនាំដល់ឃុំ សង្កាត់ ដើម្បីធានាថាឃុំ សង្កាត់នីមួយៗ មានសមត្ថភាពគ្រប់គ្រាន់ តាមរយៈការប្រើប្រាស់ថវិកាឃុំ សង្កាត់។ ប្រសិនចាំបាច់ ឃុំ សង្កាត់ អាចស្នើសុំក្រសួងមហាផ្ទៃ និងមូលនិធិជាតិជំនួយសង្គម ឱ្យរៀបចំលិខិតអន្តរក្រសួងដើម្បីស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កើនថវិកាវិភាជដល់ឃុំ សង្កាត់ សម្រាប់មុខសញ្ញាចំណាយដាក់លាក់លើការគាំទ្រធនធានមនុស្សក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់។
- មូលនិធិជាតិជំនួយសង្គមត្រូវរៀបចំកន្លែងបណ្តុះបណ្តាល ពេលបណ្តុះបណ្តាល និងសម្ភារៈគាំទ្រការបណ្តុះបណ្តាល សម្រាប់រដ្ឋបាលគ្រប់ថ្នាក់។
- មូលនិធិជាតិជំនួយសង្គមនឹងធ្វើការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងមហាផ្ទៃ, ក្រសួងផែនការ, និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឯកភាពគ្នាលើកាលវិភាគសិក្ខាសាលាបណ្តុះបណ្តាល និងកំណត់អាទិភាព
- មូលនិធិជាតិជំនួយសង្គមនឹងដាក់ចេញនូវផែនការ និងវិធីសាស្ត្របណ្តុះបណ្តាលជាជំហានៗ ដល់អ្នកអនុវត្តកម្មវិធីនៅគ្រប់កម្រិត ដោយមានការសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ
- មេរៀនបណ្តុះបណ្តាលនឹងត្រូវរៀបចំ និងអនុម័តដោយមូលនិធិជាតិជំនួយសង្គម
- មេរៀនបណ្តុះបណ្តាលប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាននឹងត្រូវបង្កើតឡើងដោយក្រុមការងារអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- មូលនិធិជាតិជំនួយសង្គមនឹងរៀបចំគ្រូបង្គោលសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អភិបាលរងរាជធានី ខេត្តទទួលបន្ទុកការងារសង្គមកិច្ច មានតួនាទីសំខាន់ ក្នុងការគាំទ្រដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការសម្របសម្រួលជាមួយមន្ទីរ និងអង្គភាព ផ្សេងៗ ដើម្បីបើកវគ្គបណ្តុះបណ្តាល
- រដ្ឋបាល រាជធានី ខេត្ត ដែលមានអភិបាលរងដឹកនាំសម្របសម្រួលជាមួយតំណាងក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធានាឱ្យមានការបណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ៨.៤. ការបញ្ជ្រាបការយល់ដឹង និងការកៀរគរការចូលរួម

សកម្មភាពកៀរគរការចូលរួម មានគោលបំណងបង្កើត និងពង្រឹងការគាំទ្ររបស់សហគមន៍លើកម្មវិធី និងលើកទឹកចិត្តឱ្យគ្រួសារក្រីក្រ និងងាយរងគ្រោះចុះឈ្មោះចូលកម្មវិធី។ ក្នុងករណីនេះ សកម្មភាពបញ្ជ្រាបការយល់ដឹង និងកៀរគរការចូលរួម ត្រូវធានាថាអ្នកទទួលផលបច្ចុប្បន្នបន្តទទួលបានការបើកផ្តល់ និងបច្ចុប្បន្នភាពព័ត៌មានថ្មីៗអំពីការផ្លាស់ប្តូរនានា ដែលអាចប៉ះពាល់ដល់ការទទួលបានការឧបត្ថម្ភពីកម្មវិធី។ សកម្មភាពកៀរគរការចូលរួម មានគោលបំណង ដូចខាងក្រោម៖

- បង្កើត និងពង្រឹងការគាំទ្ររបស់សហគមន៍ លើការអនុវត្តកម្មវិធី

- បង្កើនការយល់ដឹងដល់សហគមន៍អំពីគោលបំណងរបស់កម្មវិធី ដើម្បីបង្កើនការទទួលយកសេវាថែទាំសុខភាពមូលដ្ឋាន និងអាហារូបត្ថម្ភក្នុងចំណោមស្ត្រីមានផ្ទៃពោះ ឬស្ត្រីដែលស្ថិតក្នុងដំណាក់កាលនៃការបំបៅដោះទារកដែលទើបនឹងកើត ការទទួលយកការអប់រំ និងការជំរុញការអភិវឌ្ឍមូលធនមនុស្ស
- ឆ្លើយរាល់សំណួរ ដែលទទួលបានពីសហគមន៍ពាក់ព័ន្ធនឹងកម្មវិធី
- លើកទឹកចិត្តគ្រួសារឱ្យចុះឈ្មោះចូលកម្មវិធី និងស្វែងរកការបញ្ជូនបន្តទៅសេវាដទៃទៀតដែលមាន
- ធានាថាសហគមន៍ប្រកាន់ឥរិយាបថវិជ្ជមានចំពោះកម្មវិធី និងការចុះឈ្មោះចូលកម្មវិធី។

ការបញ្ជ្រាបការយល់ដឹង និងការកៀរគរការចូលរួម ជាសកម្មភាពដំបូងក្នុងវដ្តនៃកម្មវិធី និងជាចំណុចពាក់ព័ន្ធដំបូងរបស់អ្នកទទួលផលជាមួយនឹងកម្មវិធី។ លើសពីនេះ សកម្មភាពបញ្ជ្រាបការយល់ដឹង និងកៀរគរការចូលរួម ក៏កើតឡើងនៅគ្រប់ដំណាក់កាលក្នុងវដ្តនៃកម្មវិធី ដើម្បីធានាថាអ្នកទទួលផលបន្តទទួលបានព័ត៌មាន បន្តគាំទ្រដល់កម្មវិធី និងបង្កើតឥរិយាបថវិជ្ជមានចំពោះកម្មវិធី។ ដើម្បីសម្រេចបានគោលបំណងទាំងនេះ, កិច្ចការសំខាន់ៗមួយចំនួន គប្បីត្រូវអនុវត្តៈ

- មូលនិធិជាតិជំនួយសង្គម ត្រូវធានាថាយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានបង្កើត និងអនុវត្តយ៉ាងហោចណាស់ ៣ខែ មុនពេលសមាហរណកម្មកម្មវិធីទៅក្រោមក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ការណ៍នេះ គប្បីរួមបញ្ចូលយុទ្ធនាការចុះឈ្មោះ ដែលបង្ហាញពីការផ្លាស់ប្តូរនានារបស់កម្មវិធី ដែលជាលទ្ធផលនៃសមាហរណកម្ម។ ការផ្សព្វផ្សាយព័ត៌មានគ្រាដំបូង និងតាមកាលកំណត់ នឹងត្រូវធ្វើឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត
- មូលនិធិជាតិជំនួយសង្គម ត្រូវធានាថាមន្ត្រីឃុំ សង្កាត់ និងភូមិ ត្រូវបានកៀរគរឱ្យចូលរួម ហើយសហគមន៍បានយល់ដឹងពីការផ្លាស់ប្តូរនានា និងផលប៉ះពាល់ដែលអាចមានពីការផ្លាស់ប្តូរទាំងនោះ
- មន្ត្រីនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ និងមន្ត្រីនៃមូលដ្ឋានសុខាភិបាលសាធារណៈ នឹងបញ្ជ្រាបការយល់ដឹងដល់សហគមន៍អំពីសារៈសំខាន់នៃការពិនិត្យផ្ទៃពោះត្រឹមត្រូវ, ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ, ការថែទាំក្រោយសម្រាល, អនាម័យល្អ, និងការបំបៅកូន ព្រមទាំងកៀរគរការចូលរួមក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់, ការចុះឈ្មោះចូលរៀន និងការចូលរៀន ក៏ដូចជាការថែទាំ និងគាំទ្រជនមានពិការភាព, អ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍, និងជនចាស់ជរា
- យុទ្ធនាការចុះឈ្មោះក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ចាំបាច់ត្រូវរួមបញ្ចូលសកម្មភាពអប់រំផ្សព្វផ្សាយទូលំទូលាយ អំពីសារៈសំខាន់នៃការថែទាំសុខភាពល្អ ទឹកស្អាត អនាម័យ ការផ្តល់អាហារ និងអាហារូបត្ថម្ភ។

## ៩. វដ្តប្រតិបត្តិការ និងជំហាននៃកម្មវិធី

វដ្តនៃប្រតិបត្តិការ សំដៅដល់រយៈពេល រវាងអ្នកទទួលផលចូលក្នុងកម្មវិធី និងចាកចេញពីកម្មវិធី។ វដ្តនៃប្រតិបត្តិការមានដំណើរការជាប្រចាំ និងជាលំដាប់លំដោយចំនួនប្រាំមួយ ដូចរូបភាពខាងក្រោម ដែលបង្ហាញពីវដ្តនៃប្រតិបត្តិការ ចាប់ពីការចុះឈ្មោះ រហូតដល់សកម្មភាពដោះស្រាយបណ្តឹងតវ៉ា តាមដាន និងវាយតម្លៃ ដោយគ្រប់ដណ្តប់ ចាប់ពីពេលដែលអ្នកទទួលផលចូលក្នុងកម្មវិធី និងចាកចេញពីកម្មវិធី។

**រូបភាពទី ៤៖ វដ្តប្រតិបត្តិការ**




### ៩.១. ការកំណត់អត្តសញ្ញាណក្រុមគោលដៅ និងការចុះឈ្មោះចូលកម្មវិធី

ការកំណត់ក្រុមគោលដៅ និងការចុះឈ្មោះអ្នកទទួលផល ធ្វើឡើងតាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដោយមានឃុំសង្កាត់ ទទួលបន្ទុកលើការបញ្ចូលទិន្នន័យ ផ្ទៀងឯកសារ និងចុះឈ្មោះ។



## ៩.២. ការអនុវត្តលក្ខខណ្ឌ អនុម័ត និងការបើកផ្តល់

មុខងារទាំង៣នេះ នឹងត្រូវបានគ្រប់គ្រង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ គ្រឹះស្ថានបើកផ្តល់មានតួនាទីផ្តល់អត្ថប្រយោជន៍ដល់អ្នកទទួលផល។ រាល់ការបើកផ្តល់របស់កម្មវិធីទាំងអស់ នឹងត្រូវបានសម្របសម្រួល តាមរយៈប្រព័ន្ធផ្ទេរប្រាក់អេឡិចត្រូនិក ហើយអនុវត្តតាមដំណើរការ ដូចខាងក្រោម៖

**រូបភាពទី ៥៖ ការបើកផ្តល់ និងលក្ខខណ្ឌ**




<u>**ទម្រង់នៃការបើកផ្តល់**</u>

កម្រិត ឬភាពខុសគ្នានៃហេដ្ឋារចនាសម្ព័ន្ធ មានន័យថាទម្រង់នៃការបើកផ្តល់ ក៏មានភាពខុសគ្នាផងដែរ រវាងទីប្រជុំជន ជនបទ និងតំបន់ដាច់ស្រយាល។ ការបើកផ្តល់ទាំងអស់នឹងត្រូវធ្វើឡើងតាមរយៈការផ្ទេរទៅក្នុងគណនីរបស់អ្នកទទួលផល តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ អ្នកទទួលផលអាចដកសាច់ប្រាក់ពីបញ្ជរដកប្រាក់ ទូអេធីអឹម (ATM) ឬភ្នាក់ងារផ្ទេរប្រាក់ចល័ត តាមរយៈគណនីធនាគារដែលបានភ្ជាប់ជាមួយកម្មវិធី។ ករណីនៅតំបន់ដាច់ស្រយាលដែលមិនមានធនាគារ និងទូអេធីអឹម ឃុំ សង្កាត់ អាចផ្តល់ការគាំទ្រដល់ការដកសាច់ប្រាក់ តាមរយៈឧបករណ៍បើកផ្តល់ POS (Point-Of-Sale devices)។

## ៩.៣. ការគ្រប់គ្រងករណី

ប្រព័ន្ធគ្រប់គ្រងករណី ដែលគាំទ្រដោយក្រុមប្រឹក្សាឃុំ សង្កាត់ ជាកាតាលីករជំរុញការបង្កើនការគ្របដណ្តប់ និងអនុលោមភាពតាមលក្ខខណ្ឌរបស់កម្មវិធី។ មន្ត្រីរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ មានតួនាទីផ្តល់ប្រឹក្សា, ចុះតាមខ្ទងផ្ទះ, និងគាំទ្រការបញ្ជូនបន្ត ដើម្បីធានាថាអ្នកទទួលផលបានចុះឈ្មោះចូលកម្មវិធី និងអនុវត្តលក្ខខណ្ឌ សម្រាប់អត្ថប្រយោជន៍ដែលមានភ្ជាប់លក្ខខណ្ឌ។

**រូបភាពទី៦៖ ការគ្រប់គ្រងករណី**




## ៩.៤. ការផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ និងការរាយការណ៍

អង្គភាពនីមួយៗ ដែលទទួលបន្ទុកអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបំពេញតួនាទីផ្ទៀងផ្ទាត់ និងរាយការណ៍ ទៅតាមតួនាទីភារកិច្ចរបស់ខ្លួន និងតាមការកំណត់របស់មូលនិធិជាតិជំនួយសង្គម។

មូលនិធិជាតិជំនួយសង្គមមានភារកិច្ចក្នុងការរាយការណ៍អំពីវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ៩.៥. ការដោះស្រាយបណ្តឹងតវ៉ា

ក្នុងវដ្តនៃប្រតិបត្តិការទាំងមូល, ប្រតិបត្តិករ និងស្ថាប័នពាក់ព័ន្ធទទួលបន្ទុកអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ បើកចំហក្នុងការទទួលពាក្យបណ្តឹង និងការស្រាយបំភ្លឺពីអ្នកទទួលផល និងអ្នកមិនមែនជាអ្នកទទួលផល ពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស និងការមិនពេញចិត្តរបស់ពួកគេចំពោះការប្រព្រឹត្ត របស់អ្នកអនុវត្តកម្មវិធី ឬអ្នកពាក់ព័ន្ធផ្សេងទៀត។

### ៩.៥.១. បញ្ហាបច្ចេកទេសដែលកើតឡើងជាប្រចាំ

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ប្រើប្រាស់យន្តការដែលបាន និងកំពុងអនុវត្តក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ សម្រាប់ការដោះស្រាយបញ្ហាបច្ចេកទេសដែលកើតឡើងជាប្រចាំ ដើម្បីធានាថាដំណើរការក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារប្រព្រឹត្តទៅដោយរលូន។

### ៩.៥.២. ការដោះស្រាយបណ្តឹងតវ៉ា និងវិវាទ

ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ប្រើប្រាស់យន្តការបណ្តឹងតវ៉ា និងវិវាទ ដែលមានលក្ខណៈងាយស្រួលសម្រាប់ការប្រើប្រាស់ ដោយរក្សាអនាមិកភាពក្នុងករណីចាំបាច់ និង ផ្អែកលើបទពិសោធន៍នៃយន្តការបណ្តឹងតវ៉ា និងវិវាទរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងនោះការដាក់ពាក្យបណ្តឹងមានច្រើនសណ្ឋាន រួមមានដាក់ពាក្យបណ្តឹង ផ្ទាល់ទៅឃុំ សង្កាត់ ឬតាមរយៈ មេភូមិ ឬដាក់ក្នុងប្រអប់សំបុត្រទទួលពាក្យបណ្តឹងនៅសាលាឃុំ សង្កាត់ ឬតាមរយៈលេខទូរសព្ទទាន់ហេតុការណ៍។ បណ្តឹងអនាមិក និងបណ្តឹងដាក់លាក់ទាំងអស់ ត្រូវបានកត់ត្រា និងគ្រប់គ្រង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ មេឃុំ ចៅសង្កាត់ ត្រូវកត់ត្រា បណ្តឹងដែលទទួលបាន ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ ពាក្យបណ្តឹងដែលធ្វើឡើងតាមរយៈ បណ្តាញទូរសព្ទទាន់ហេតុការណ៍ ក៏ត្រូវបានកត់ត្រាដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ផងដែរ។

បណ្តឹងតវ៉ា និងវិវាទ ត្រូវបានដោះស្រាយនៅ ៣កម្រិត រួមមានកម្រិតប្រតិបត្តិករ, កម្រិត អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម, និងកម្រិតតុលាការ។ គោលការណ៍ណែនាំស្តីពី ការដោះស្រាយបណ្តឹងតវ៉ា និងវិវាទនៅកម្រិតប្រតិបត្តិករ និងកម្រិតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគាំពារសង្គម នឹងត្រូវបានបង្កើតឡើង។

## ៩.៦. ការតាមដាន និងការវាយតម្លៃ

យន្តការតាមដាន និងវាយតម្លៃក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារនឹងត្រូវបាន រៀបចំឡើង ដោយបន្សីជាមួយយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដើម្បីតាមដាន និង វាយតម្លៃកម្មវិធីនីមួយៗក្រោមក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

### ៩.៦.១. ការតាមដាន

យន្តការតាមដាន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នឹងគាំទ្រការតាមដានការអនុវត្ត កម្មវិធីជាប្រចាំ។ មូលនិធិជាតិជំនួយសង្គម មានភារកិច្ចតាមដានការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុង កញ្ចប់គ្រួសារ នៅកម្រិតកម្មវិធីជាប្រចាំ ដោយមានការគាំទ្រពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ គាំពារសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដែលមានតួនាទីគាំទ្រការតាមដាន និងវាយតម្លៃ ដូចជារដ្ឋបាល ក្រុង ស្រុក ខណ្ឌ ជាដើម។

គោលបំណងសំខាន់ៗនៃការតាមដាន រួមមាន៖

- ស្វែងយល់អំពីភាពជាប់ពាក់ព័ន្ធ (Relevancy) របស់កម្មវិធី និងពិនិត្យវឌ្ឍនភាព របស់កម្មវិធី
- វាយតម្លៃការអនុវត្តកម្មវិធី និងការបើកផ្តល់ ដើម្បីធានាថាដំណើរការកម្មវិធីប្រព្រឹត្ត ដោយរលូន
- កំណត់រកភាពរាំងស្ទះ និងបញ្ហាប្រឈមក្នុងការអនុវត្ត និងធ្វើការដោះស្រាយឱ្យបាន ទាន់ពេល
- ធានាបាននូវគណនេយ្យភាព និងតម្លាភាពចំពោះអ្នកពាក់ព័ន្ធទាំងអស់។

### ៩.៦.២. ការវាយតម្លៃ

ការវាយតម្លៃ មានសារៈសំខាន់សម្រាប់ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលត្រូវធ្វើឡើងតាមកាលកំណត់ជាក់លាក់ ក្រោយដាក់ឱ្យដំណើរការក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារបានមួយរយៈពេល ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង, ស្វែងរកបច្ច័យ និងលទ្ធផលចុងក្រោយនៃក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ, ពិនិត្យលើការឆ្លើយតបនឹងគោលបំណងរបស់កម្មវិធីប្រកបដោយស័ក្តិសិទ្ធិភាព និងពិនិត្យលើប្រសិទ្ធភាពចំណាយ។ ការវាយតម្លៃលើដំណើរការកម្មវិធីតាមកាលកំណត់ជាក់លាក់ ឬការវាយតម្លៃលើផលជះក៏ត្រូវធ្វើឡើងនៅកម្រិតកម្មវិធី (សម្រាប់កម្មវិធីនីមួយៗ) ផងដែរ។ ការវាយតម្លៃនេះ ត្រូវដឹកនាំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានការគាំទ្រពីក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងន័យពង្រឹង និងកែលម្អការអនុវត្តកម្មវិធី និងពង្រីកវិសាលភាពគ្របដណ្តប់។

## ១០. ផែនការសមាហរណកម្ម និងការពង្រីកវិសាលភាព

ផែនការសមាហរណកម្ម និងពង្រីកវិសាលភាពកម្មវិធីមានម៉ូដែល ដូចតារាងខាងក្រោម។ កម្មវិធីអាហាររូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា នឹងត្រូវសមាហរណកម្មចូលក្នុងឆ្នាំទី២ នៃការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងពង្រីកវិសាលភាពគ្របដណ្តប់លើសិស្សក្រីក្រទូទាំងប្រទេស។ វិសាលភាពគ្របដណ្តប់នៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពក្រីក្រនឹងកើនឡើងដោយអនុវត្តសម្រាប់ទូទាំងប្រទេសនៅពេលសមាហរណកម្ម។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា នឹងត្រូវបានបង្កើតឡើងក្នុងកញ្ចប់គ្រួសារ ដោយមានវិសាលភាពគ្របដណ្តប់លើជនចាស់ជរាក្រីក្រទូទាំងប្រទេស។

| កម្មវិធី | ២០២៣ | ២០២៤ | ២០២៥ តទៅ |
|---|---|---|---|
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ | បន្តអនុវត្ត និងរៀបចំយន្តការសមាហរណកម្មចូលក្នុងកញ្ចប់គ្រួសារ | សមាហរណ៍ និងអនុវត្តជាកញ្ចប់គ្រួសារ | |
| កម្មវិធីអាហាររូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា | បន្តអនុវត្ត និងរៀបចំយន្តការសមាហរណកម្មចូលក្នុងកញ្ចប់គ្រួសារ | បន្តអនុវត្ត និងរៀបចំយន្តការសមាហរណកម្មចូលក្នុងកញ្ចប់គ្រួសារ | សមាហរណ៍ និងអនុវត្តជាកញ្ចប់គ្រួសារ ដោយពង្រីកវិសាលភាពទូទាំងប្រទេស |
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព | កែសម្រួលយន្តការ និងរៀបចំយន្តការសមាហរណកម្មចូលក្នុងកញ្ចប់គ្រួសារ | សមាហរណ៍ និងអនុវត្តជាកញ្ចប់គ្រួសារ ដោយពង្រីកវិសាលភាពទូទាំងប្រទេស | |
| កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរាចាប់ពី ៦០ឆ្នាំឡើង | រៀបចំបង្កើតកម្មវិធីស្របតាមយន្តការអនុវត្តក្នុងកញ្ចប់គ្រួសារ | អនុវត្តជាកញ្ចប់គ្រួសារ ដោយមានវិសាលភាពទូទាំងប្រទេស | |
| ការឧបត្ថម្ភជូនសមាជិកគ្រួសារមានផ្ទុកមេរោគ/ជំងឺអេដស៍ | រៀបចំយន្តការអនុវត្តក្នុងកញ្ចប់គ្រួសារ | អនុវត្តជាកញ្ចប់គ្រួសារ | |
| ការឧបត្ថម្ភគោលសម្រាប់គ្រួសារ | រៀបចំយន្តការអនុវត្តក្នុងកញ្ចប់គ្រួសារ | អនុវត្តជាកញ្ចប់គ្រួសារ | |

## ១១. សេចក្តីសន្និដ្ឋាន

គោលការណ៍ណែនាំស្តីពី ការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ឆ្លើយតបនឹងគោលដៅរបស់ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដោយរួមចំណែកក្នុងការបង្កើនការគ្របដណ្តប់ និងការបំពេញបន្ថែមតម្រូវការចាំបាច់ពេញមួយវដ្តជីវិត ចាប់ពីពេលចាប់កំណើត រហូតដល់ទទួលមរណភាព ដោយបានពង្រឹងស្ថានភាពគ្រួសារ ការកសាងសង្គមមួយឱ្យមានភាពធន់ និងការវិនិយោគលើមូលធនមនុស្ស ប្រកបដោយបរិយាបន្ន និងចីរភាព។

ការធ្វើសមាហរណកម្មពីកម្មវិធីជំនួយសង្គមនានា ទៅជា **ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** នឹងធ្វើឱ្យកម្មវិធីនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ, លទ្ធភាពទទួលបានអត្ថប្រយោជន៍, ពង្រីកវិសាលភាពគ្របដណ្តប់ ពង្រឹងក្របខណ្ឌស្ថាប័ន និងសមាហរណកម្មប្រព័ន្ធរួមមួយ ដែលធ្វើឱ្យប្រតិបត្តិការជំនួយសង្គមមានលក្ខណៈស្ថាប័នូបនីយកម្ម និងឌីជីថលូបនីកម្មប្រព័ន្ធ ជាពិសេសអាចឆ្លើយតបនឹងវិបត្តិ តាមរយៈស្វ័យប្រវត្តិកម្ម។

ការអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ តាមយន្តការអន្តរក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងស្ថាប័នដៃគូ ជួយពង្រឹងកិច្ចសហការ និងអភិបាលកិច្ចល្អ ក្នុងការអនុវត្តកម្មវិធីឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ទាំងការអនុវត្តមុខងាររបស់ប្រតិបត្តិករ និងការទទួលបានសេវាកម្មរបស់អ្នកទទួលផល។

ជារួម គោលការណ៍ណែនាំអនុវត្តក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ បានបង្ហាញពីទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងការគ្រប់គ្រង និងការអនុវត្តកម្មវិធីដើម្បីចូលរួមចំណែកលើកកម្ពស់ស្ថានភាព គ្រួសារក្រីក្រ គ្រួសារងាយរងហានិភ័យ និងជនងាយរងគ្រោះស្របតាមដំណើរការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា និងធានាដល់ការសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០។

# សទ្ទានុក្រម

**ប្រព័ន្ធគាំពារសង្គម** សំដៅដល់គោលនយោបាយ, កម្មវិធី, សកម្មភាព, ក្របខណ្ឌច្បាប់ និងក្របខណ្ឌស្ថាប័ន ដែលត្រូវបានរៀបចំដើម្បីផ្តល់ការគាំពារ និងពង្រឹងសមត្ថភាពរបស់ពលរដ្ឋកម្ពុជាក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រឈមនូវហានិភ័យផ្នែកសេដ្ឋកិច្ច-សង្គម និងភាពងាយរងគ្រោះផ្សេងៗ ដែលបណ្តាលមកពីបម្រែបម្រួលលក្ខខណ្ឌរស់នៅ និងការងារ ដូចជាការធ្លាក់ចូលទៅក្នុងភាពក្រីក្រដែលបណ្តាលមកពីការទទួលរងឥទ្ធិពលពីគ្រោះធម្មជាតិ, តម្រូវការលើការថែទាំសុខភាព, ការធ្លាក់ខ្លួនពិការភាព ឬការឈានចូលវ័យចាស់ជរា ជាដើម។

**ប្រព័ន្ធជំនួយសង្គម** សំដៅដល់អន្តរាគមន៍សម្រាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ដែលហិរញ្ញប្បទានដោយប្រភពចំណូលពីថវិកាជាតិ និង/ឬជំនួយអភិវឌ្ឍន៍ផ្លូវការ។ កិច្ចអន្តរាគមន៍ទាំងនោះ រួមមាន៖ (១) ការឆ្លើយតបនឹងគ្រោះអាសន្ន (២) ការអភិវឌ្ឍមូលធនមនុស្ស (៣) ការបណ្តុះបណ្តាលវិជ្ជាជីវៈ (៤) សុខុមាលភាពសម្រាប់ជនងាយរងគ្រោះ។

**ប្រព័ន្ធសន្តិសុខសង្គម** សំដៅដល់កម្មវិធី និងរបបគាំពារសង្គម ដែលផ្តល់ការគាំពារដល់ពលរដ្ឋពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ, លំហែមាតុភាព, គ្រោះថ្នាក់ការងារ, និកម្មភាព, ទុព្វលភាព, ជរាភាព និងមរណភាពរបស់អ្នកដែលរកប្រាក់ចំណូលចិញ្ចឹមគ្រួសារ ដូចជា៖ (១) សោធន, (២) ការថែទាំសុខភាព, (៣) ហានិភ័យការងារ, និង (៤) និកម្មភាព ជាដើម។ របបសន្តិសុខសង្គម តម្រូវឱ្យ សមាជិក និងភាគីពាក់ព័ន្ធ បង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើគោលការណ៍ផ្តល់ឧបត្ថម្ភធនជូនដល់ពលរដ្ឋ ដែលមិនមានលទ្ធភាពបង់ភាគទាន ពោលគឺពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។

**ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ** សំដៅដល់សមាហរណកម្មកម្មវិធីជាតិជំនួយសង្គមមានលក្ខណៈជាការឧបត្ថម្ភសាច់ប្រាក់ ឱ្យមកអនុវត្តក្នុងទម្រង់យន្តការអនុវត្តរួម ក្រោមប្រតិបត្តិករទោលមួយ ក្នុងគោលបំណងពង្រឹងអភិបាលកិច្ច និងបង្កើនប្រសិទ្ធភាព សង្គតិភាព និងពង្រីកការគ្របដណ្តប់ ឱ្យបានកាន់តែទូលំទូលាយ។

**កិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន** សំដៅដល់ការប្រើប្រាស់សក្តានុពលនៃប្រព័ន្ធគាំពារសង្គមដើម្បីកាត់បន្ថយភាពរងឥទ្ធិពលពីគ្រោះអាសន្ននានា ដែលបង្កផលប៉ះពាល់លើសហគមន៍, ថ្នាក់តំបន់, ឬថ្នាក់ជាតិ ដើម្បីផ្តល់ការគាំទ្រដល់គ្រួសារដែលទទួលរងផលប៉ះពាល់ដោយគ្រោះអាសន្ន។

**មូលដ្ឋានទិន្នន័យចុះបញ្ជីសង្គម(Social Protection Registry)** សំដៅដល់ឃ្លាំងផ្ទុកទិន្នន័យចុះបញ្ជី, លក្ខណវិនិច្ឆ័យ ឬអត្តសញ្ញាណ ពលរដ្ឋដែលជាក្រុមគោលដៅ ដែលអាចនឹងត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធី និងរបបក្នុងប្រព័ន្ធគាំពារសង្គម។

**ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន (MIS)** សំដៅដល់ប្រព័ន្ធ ឬកម្មវិធី Software សម្រាប់ការគ្រប់គ្រងព័ត៌មានរបស់កម្មវិធី តាមរយៈការកត់ត្រា ការបញ្ចូល ការបញ្ជូន ការទុកដាក់ និងការរាយការណ៍។

**អភិក្រមហានិភ័យនៃវដ្តជីវិត** សំដៅដល់ការគិតគូរអំពីហានិភ័យនៃវដ្តជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូប ទៅតាមដំណាក់កាលនីមួយៗ ចាប់តាំងពីការចាប់កំណើត រហូតដល់មរណៈភាព។ បុគ្គលម្នាក់ៗ ប្រឈមនឹងហានិភ័យ និងភាពងាយរងគ្រោះខុសៗគ្នា។

**កម្លាំងសេវាសង្គម** សំដៅដល់ជនទាំងឡាយណា ទាំងមន្ត្រីរាជរដ្ឋាភិបាល បុគ្គលិកសមាគម និង អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរូបវន្តបុគ្គល ទោះជាអ្នកអាជីព អ្នកអាជីពរង ឬអ្នកមាន ជំនាញច្បាស់លាស់ផ្នែកការងារសង្គមកិច្ច ដោយយកកម្រៃ ឬមិនយកកម្រៃ ធ្វើការដើម្បីធានាបាន នូវការអភិវឌ្ឍសុខុមាលភាពរបស់អតិថិជន។

**សេវាសង្គមកិច្ច** សំដៅដល់ការដឹកនាំគ្រប់គ្រងសេវាសង្គម រួមមានគោលនយោបាយសង្គមកិច្ច យុទ្ធសាស្ត្រ និងផែនការនៃការផ្តល់សេវាសង្គម។ ចំណែក **សេវាសង្គម** ជាប្រព័ន្ធរៀបរយមួយនៃ សេវាកម្ម និងកម្មវិធីរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើការទប់ស្កាត់ កាត់បន្ថយ ឬដោះស្រាយហានិភ័យ ផ្នែកសង្គម ឬបញ្ហាសង្គម ដោយធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់បុគ្គល គ្រួសារ និងសហគមន៍ ណាមួយ។ អត្ថប្រយោជន៍ដែលផ្តល់ឱ្យត្រូវផ្អែកលើទស្សនៈវិស័យ ឬជម្រើសមួយស្តីពីសិទ្ធិ។

**ប្រព័ន្ធបញ្ជូនបន្ត និងបណ្តាញតភ្ជាប់** សំដៅដល់ការរៀបចំមូលដ្ឋានគ្រឹះនានាដែលធានាដល់ការ ពង្រឹង និងការទទួលបានសេវារបស់អ្នកទទួលផល។ ប្រព័ន្ធនេះអាចធ្វើឱ្យបុគ្គល និងគ្រួសារដែល មានលក្ខខណ្ឌគ្រប់គ្រាន់ មានភាពងាយស្រួលក្នុងការទទួលអត្ថប្រយោជន៍ ឬត្រូវបានបញ្ជូនបន្ត ទៅទទួលផលពីកម្មវិធី ឬរបបក្រោមប្រព័ន្ធគាំពារសង្គម និងសេវាសង្គមផ្សេងៗទៀត។

**ការគ្រប់គ្រងករណី** សំដៅដល់ដំណើរការនៃការវាយតម្លៃ ការរៀបចំផែនការ ការអនុវត្តសកម្មភាព ការសម្របសម្រួល ការត្រួតពិនិត្យ និងវាយតម្លៃជម្រើស និងសេវា ដើម្បីធានាការឆ្លើយតប ចំពោះអ្នកទទួលផល។

**អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន** សំដៅដល់ការកំណត់ស្ថានភាពជន មានពិការភាព ដែលរួមមានស្ថានភាពបុគ្គលពាក់ព័ន្ធនឹងអាយុ ភេទ និងស្ថានភាពគ្រួសារ ស្ថានភាព ពិការភាពពាក់ព័ន្ធនឹងប្រភេទ កម្រិតពិការភាព និងតម្រូវការសេវា និងបរិស្ថានរស់នៅ ដូចជា ផាសុកវត្ថុ និងផាសុកសមរម្យ ស្របទៅតាមលក្ខណៈវិនិច្ឆ័យតាមប្រភេទ និងកម្រិតពិការភាព។

**គ្រឹះស្ថានបើកផ្តល់** សំដៅដល់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលមានច្បាប់អនុញ្ញាត ដែលបានចុះ អនុស្សារណៈយោគយល់គ្នាជាមួយស្ថាប័នប្រតិបត្តិករ ដើម្បីផ្តល់សេវាផ្ទេរសាច់ប្រាក់ដល់អ្នកទទួល ផលរបស់កម្មវិធី។

គាំពារ សង្គម កម្ពុជា